


# ការគ្រប់គ្រងជីជាតិដីលើដំណាំស្រូវនៅកម្ពុជា











បោះពុម្ពលើកទី ២

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Cambodian Agricultural Research and Development Institute

# ការគ្រប់គ្រងជីជាតិដីលើដំណាំស្រូវ នៅកម្ពុជា

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

Cambodian Agricultural Research and Development Institute (CARDI)

២០១០

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានត្រូវបង្កើតឡើងដោយអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ១៩៩៩ ដោយរាជរដ្ឋាភិបាលកម្ពុជា ជាគ្រឹះស្ថានសាធារណៈ មានលក្ខណៈរដ្ឋបាល ក្នុងគោលបំណងលើកស្ទួយកម្រិតជីវភាពរបស់ប្រជាកសិករកម្ពុជា តាមរយៈការអភិវឌ្ឍបច្ចេកវិទ្យាសមស្របដើម្បីបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ក្រោមទស្សនទាន "ជាដៃគូសម្រាប់ធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅ និងកំណើនសេដ្ឋកិច្ច"។

រក្សាសិទ្ធិ ២០១០
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

ប្រអប់សំបុត្រលេខ ០១ ភ្នំពេញ កម្ពុជា
ផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ៖ (៨៥៥ ២៣) ៦៣១៩ ៦៩៣-៤
ទូរសារ៖ (៨៥៥ ២៣) ២១៩ ៨០០
ទូរអក្ខរ៖ cardi@cardi.org.kh
គេហទំព័រ៖ www.cardi.org.kh

បោះពុម្ពលើកទី ១ ឆ្នាំ ២០០៨
បោះពុម្ពលើកទី ២ ឆ្នាំ ២០១០
រៀបចំ និងរចនាទូទៅដោយ លោក ស៊ីវ ពិសី និង លោក ទ្រី សុខសាន្ត

បោះពុម្ពនៅក្នុងព្រះរាជាណាចក្រកម្ពុជា

Cambodian Agricultural Research and Development Institute (CARDI)

# បុព្វកថា

**ដំណើរ**ការអភិវឌ្ឍនៅកម្ពុជា បានឈានមកដល់ផ្លូវបំបែកហើយ ដោយបានឆ្លងកាត់តំណាក់កាលនៃការស្តារ និងកសាងឡើងវិញ តាមរយៈការតម្រង់ត្រីវិស័យឆ្ពោះទៅរកការអភិវឌ្ឍមួយដែលកាន់តែមាននិរន្តរភាព ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**ទន្ទឹម**នឹងនេះ ដោយសារការខិតខំប្រឹងប្រែងយ៉ាងពេញទំហឹង ក្នុងវិស័យយោបាយទឹក ជាពិសេសការអនុវត្តន៍ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យកសិកម្មពិតមែនតែមានវិសាលភាពធំ ក៏ប៉ុន្តែបានចាប់ផ្តើមងើបឡើងគួរឲ្យកត់សម្គាល់។ ទោះបីជាយ៉ាងណាក៏យើងនៅតែទទួលស្គាល់ថាវិស័យនេះនៅមានភាពរណបលើធម្មជាតិស្ទើរទាំងស្រុង។ រីឯលទ្ធភាពផ្គត់ផ្គង់សេវាបច្ចេកទេសផ្សេងៗ ដើម្បីលើកកម្ពស់កំណើនផលិតភាពកសិកម្ម ក៏ដូចជាការបង្កើនចំណូលដល់គ្រួសារដែលកំពុងរស់នៅពឹងផ្អែកលើវិស័យកសិកម្ម ក៏ពុំទាន់ឆ្លើយតបឲ្យបានសមរម្យតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ប្រមុខនៃរាជរដ្ឋាភិបាលនៅឡើយ។

**ក្នុង**បរិការណ៍នេះ ក្រោមការជួយឧបត្ថម្ភគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងកិច្ចសហការជាមួយវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) គម្រោងការផ្ទេរបច្ចេកវិទ្យាដំណាំស្រូវ តាមប្រព័ន្ធព័ត៌មានវិទ្យា (LEARN-IT) បានចាប់ផ្តើមនៅឆ្នាំ ២០០៦ ដោយមានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាអ្នកសម្របសម្រួល និងមានការចូលរួមអនុវត្តពីអង្គភាពចំនួន ០៤ ទៀត គឺសកលវិទ្យាល័យភូមិន្ទកសិកម្ម នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និងអង្គការស្រែខ្មែរ ក្នុងគោលបំណងលើកស្ទួយ និងជួយប្រជាកសិករដែលប្រកបការដាំដុះដំណាំស្រូវជាមូលដ្ឋាន ឲ្យមានជីវភាពធូរធារ តាមរយៈការបញ្ជ្រាបបច្ចេកទេសតាមប្រព័ន្ធព័ត៌មានវិទ្យា ការបណ្តុះបណ្តាល និងការបោះពុម្ពផ្សាយ។

**ឆ្លើយ**តបទៅនឹងគោលបំណងខាងលើ ក្រុមការងារបច្ចេកទេសនៃអង្គភាពអនុវត្តគម្រោងទាំង ៥ បានខិតខំប្រឹងប្រែងរៀបចំ និងបង្កើតឲ្យមានឃ្លាំងចំណេះដឹងអំពីស្រូវនេះឡើង ដែលក្នុងនោះមានអត្ថបទបច្ចេកទេសសាមញ្ញជាក់លាក់ និងសំបូរបែប ពាក់ព័ន្ធនឹងការដាំដុះដំណាំស្រូវ ដូចជាបច្ចេកទេសបន្សុទ្ធគ្រាប់ពូជ ការដាំដុះ ការគ្រប់គ្រងជីជាតិដី ការគ្រប់គ្រងទឹកក្នុងស្រែ ការច្រូតកាត់ ប្រមូលផល និងការទុកដាក់ជាដើម។ អត្ថបទបច្ចេកទេសទាំងនេះ ត្រូវបានឆ្លងកាត់ការពិនិត្យពិគ្រោះយោបល់យ៉ាងល្អិតល្អន់ពីក្រុមការងារ ព្រមទាំងទទួលបានការឯកភាពពីក្រុមប្រឹក្សាពិនិត្យ ដែលមានសមាសភាពមកពីអង្គភាពជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ដូច**នេះឃ្លាំងចំណេះដឹងអំពីស្រូវ គឺជាពុទ្ធិមួយថ្មីទៀត ដែលមានសារៈប្រយោជន៍ឥតគណនា សម្រាប់មន្ត្រីបច្ចេកទេស មន្ត្រីផ្សព្វផ្សាយកសិកម្ម អង្គការនានាជាដៃគូ និងអ្នកពាក់ព័ន្ធដទៃទៀត យកទៅប្រើប្រាស់ដើម្បីរួមចំណែកដោះស្រាយនូវរាល់បញ្ហាប្រឈមទាំងឡាយ ដែលប្រជាកសិករកំពុងជួបប្រទះនៅក្នុងដំណើរផលិតកម្មដំណាំស្រូវ និងធ្វើយ៉ាងណាជួយជម្រុញឲ្យទិន្នផលស្រូវរបស់ប្រជាកសិករកើនឡើង ដោយបច្ចុប្បន្ននេះទិន្នផលស្រូវនៅមានកម្រិតទាប បើប្រៀបធៀបជាមួយបណ្តាប្រទេសជិតខាង។ ទទ្បីករណ៍ដែលបានលើកឡើងខាងលើ

Cambodian Agricultural Research and Development Institute (CARDI)

នេះ គឺជាភស្តុតាងយ៉ាងប្រត្យ័ក្ស បង្ហាញនូវការយកចិត្តទុកដាក់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះប្រជាកសិករក្នុងការទទួលបាននូវបច្ចេកវិទ្យាថ្មីៗ និងជាចលករមួយបង្កលក្ខណៈឲ្យប្រជាកសិករមានជីវភាពធូរធារសំបូររុងរឿងស្របតាមទិសដៅអភិវឌ្ឍ សហសវត្សរ៍ថ្មី និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

**ក្រសួង**កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសេចក្តីសង្ឃឹមដោយសុទិដ្ឋិនិយមថា គំនិតផ្តួចផ្តើមនៃការរៀបចំនូវឃ្លាំងចំណេះដឹងអំពីស្រូវដ៏មានសារៈសំខាន់នេះ នឹងក្លាយទៅជាឧបករណ៍ស័ក្តិសិទ្ធិមួយថ្មីទៀតយ៉ាងពិតប្រាកដសម្រាប់បម្រើផលប្រយោជន៍ដល់ប្រជាកសិករទូទាំងប្រទេសដែលមានបរិមាណជាង ៨០ ភាគរយ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការឧបត្ថម្ភរបស់គម្រោង ADB ក្នុងបុព្វហេតុនេះ ហើយសង្ឃឹមថាអង្គភាពជំនាញក៏ដូចជាដៃគូពាក់ព័ន្ធទាំងឡាយ នឹងខិតខំជួយពង្រីក ផ្សព្វផ្សាយចំណេះដឹងនេះឲ្យមានវិសាលភាពទូលំទូលាយជាតិយេ្យាភាព។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៨

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ច័ន្ទ សារុន**

Cambodian Agricultural R (C elopment Institute

# សេចក្តីថ្លែងអំណរគុណ

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ដែលបានផ្តល់អត្ថបទដ៏មានសារៈសំខាន់ ក្នុងការរៀបចំចងក្រងឲ្យមានជាសៀវភៅនេះឡើង។

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលបានផ្តល់ជាថវិកាសម្រាប់ការបោះពុម្ពសៀវភៅនេះលើកទី ១

គម្រោងការផ្ទេរបច្ចេកវិទ្យាដំណាំស្រូវតាមប្រព័ន្ធព័ត៌មានវិទ្យា (LEARN-IT) ដែលបានផ្តល់ជាថវិកាសម្រាប់ការបោះពុម្ពសៀវភៅនេះលើកទី ១

គម្រោង ImAgE Project ដែលបានផ្តល់ជាថវិកាសម្រាប់ការបោះពុម្ពសៀវភៅនេះលើកទី ២


Cambodian Agricultural Research and Development Institute (CARDI)

Cambodian Agricultural Research and Development Institute
(CARDI)

# មាតិកា


| ល.រ | ចំណងជើង | ទំព័រ |
|---|---|---|
| ០១ | ការធ្វើចំណាត់ថ្នាក់ដីលើដំណាំស្រូវនៅកម្ពុជា | ១ |
| ០២ | របៀបប្រើដី N P K សម្រាប់ដំណាំស្រូវ | ២២ |
| ០៣ | បម្រើបម្រាស់ "អាសូត" ក្នុងផលិតកម្មដំណាំស្រូវ | ២៧ |
| ០៤ | ការពុលជាតិដែកលើដំណាំស្រូវ | ៣០ |
| ០៥ | ការពុលជាតិប្រៃលើដំណាំស្រូវ | ៣២ |
| ០៦ | របៀបធ្វើជីកំប៉ុស្ដិ៍ | ៣៤ |


Cambodian Agricultural Research and Development Institute (CARDI)

Cambodian Agricultural Research and Development Institute (CARDI)

# ការធ្វើចំណាត់ថ្នាក់ដីលើដំណាំស្រូវនៅប្រទេសកម្ពុជា

## ១. អធិប្បាយទូទៅ

**ការយល់ដឹងអំពីដី** គឺជាការងារលំបាកមួយសម្រាប់មនុស្សភាគច្រើន ទោះបីបិតក្នុងកាលៈទេសៈសមស្របយ៉ាងណាក៏ដោយ។ នៅប្រទេសកម្ពុជា កិច្ចការនេះវានឹងរឹតតែលំបាកទៅទៀត ដោយសារយើងខ្វះខាតនូវព័ត៌មាននានាសម្រាប់ការងារនេះ។ ការយល់ដឹងអំពីការធ្វើចំណាត់ថ្នាក់ដី និងការប្រើប្រាស់ដីសម្រាប់ផលិតកម្មស្រូវនៅកម្ពុជា ជាបញ្ហាចម្បងមួយក្នុងចំណោមបញ្ហាជាច្រើន។

**ឯកសារចងក្រងនេះ** ផ្តល់នូវវិធីសាស្ត្រដ៏ងាយស្រួលមួយ ដើម្បីធ្វើអត្តសញ្ញាណដីសម្រាប់ដំណាំស្រូវ។ គន្លឹះនៃការធ្វើអត្តសញ្ញាណដីមានភាពសាមញ្ញក្នុងការប្រើប្រាស់លើបណ្តាដីសំខាន់ៗ ដែលត្រូវបានបែងចែកទៅជាក្រុមមួយចំនួន ដែលងាយគ្រប់គ្រង និងសម្គាល់។ ការពិពណ៌នាទូទៅអំពីក្រុមដីនីមួយៗ ផ្តល់ឱកាសក្នុងការត្រួតពិនិត្យឡើងវិញ បើសិនជាមានការមន្ទិលសង្ស័យទៅលើចំណាត់ថ្នាក់ដីណាមួយ។ នាបច្ចុប្បន្នការធ្វើចំណាត់ថ្នាក់ដីទាំងនេះ អ្នកអនុវត្តមិនចាំបាច់ត្រូវការផែនទីលម្អិត ឬការវិភាគនៅមន្ទីរពិសោធន៍ដ៏សាំញ៉ាំទេ។ ឯកសារនេះនឹងអធិប្បាយលម្អិតសម្រាប់អ្នកប្រើប្រាស់នូវសក្តានុពលភាពនៃក្រុមដីនីមួយៗ ម៉្យាងទៀតអ្នកបច្ចេកទេសកសិកម្មដែលកំពុងធ្វើការនៅលើវាលស្រែ នឹងពឹងផ្អែកលើឯកសារនេះដោយពិតប្រាកដសម្រាប់រយៈពេលវែងនាពេលអនាគត ។

**បន្ថែមពីលើនេះទៀត** មន្ត្រីក្សេត្រសាស្ត្រ និងផ្សព្វផ្សាយកសិកម្មថ្នាក់ខេត្ត/ក្រុង និងថ្នាក់ស្រុក នឹងប្រើប្រាស់ឯកសារនេះ ជាជំនួយធ្វើឲ្យមានការរីកចម្រើនដល់កសិករក្នុងការអនុវត្តន៍ទៅលើការគ្រប់គ្រងដីធ្លី។ ឯកសារចងក្រងនេះ នឹងមានសារៈប្រយោជន៍ផងដែរ នៅតាមបណ្តាសកលវិទ្យាល័យ មហាវិទ្យាល័យ និងសាលាកសិកម្មនានា ដើម្បីជាទុនសម្រាប់ការស្រាវជ្រាវ។ ជាទូទៅចំណាត់ថ្នាក់ដី គឺអាចធ្វើនៅគ្រប់ទីកន្លែងនៃដីដាំដុះស្រូវក្នុងប្រទេសកម្ពុជា។

### *គោលបំណង និងសារៈប្រយោជន៍*

**ណែនាំ**ឲ្យគេស្គាល់អំពីក្រុមដីសំខាន់ៗសម្រាប់ដាំដុះដំណាំស្រូវនៅប្រទេសកម្ពុជា និងចេះធ្វើចំណាត់ថ្នាក់ដីទាំងនោះ ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានដីប្រកបដោយនិរន្តរភាព។

## ២. គោលការណ៍បច្ចេកទេស

### ២.១ ទស្សនៈទូទៅអំពីការធ្វើចំណាត់ថ្នាក់ដី

ប្រព័ន្ធចំណាត់ថ្នាក់ដែលប្រើមានបីគឺ ចំណាត់ថ្នាក់តាមក្រុមដី ចំណាត់ថ្នាក់តាមអនុក្រុមដី និងចំណាត់ថ្នាក់តាមកម្រិតជីជាតិនៃដី។ ក្រុមដីត្រូវបានកំណត់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃដើមកំណើតដី និងលើលក្ខណៈរូបសាស្ត្ររបស់ដីជាចម្បង។ ចំណាត់ថ្នាក់តាមអនុក្រុមដីបានកំណត់ដោយផ្អែកលើលក្ខណៈក្សេត្រវិទ្យា និងលក្ខណៈរបស់ដីដែលមានឥទ្ធិពលលើផលិតកម្មដំណាំ ជាកត្តាសម្គាល់អនុក្រុម។ ចំណាត់ថ្នាក់តាមកម្រិតជីជាតិ គឺជាការវាយតម្លៃគុណភាពកម្រិតជីជាតិរបស់ដី ហើយវាផ្តល់គោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រង។ ចំណាត់ថ្នាក់នេះផ្អែកលើដីពីរស្រទាប់ វាយតម្លៃ គឺស្រទាប់ដីលើ និងស្រទាប់ដីក្រោម។ បើមិនអាចញែកឲ្យឃើញភាពខុសគ្នាទេ ស្រទាប់ដីខាងលើគឺជាស្រទាប់ដែលត្រូវបានភ្ជួររាល់ឆ្នាំ ឬដីស្រទាប់លើកម្រាស់ ២០ ស.ម។ ដីដែលនៅពីក្រោមបន្ទាប់ពីស្រទាប់លើហៅថាដីស្រទាប់ក្រោម។ បើលោកអ្នកមិនអាចញែកឲ្យឃើញភាពខុសគ្នាច្បាស់លាស់ទេ ដី

Cambodian Agricultural Research and Development Institute (CARDI)

ស្រទាប់ក្រោមត្រូវបានចាត់ទុកថាមានជម្រៅ ៥០ ស.ម។

ការកំណត់លក្ខណៈរបស់ដី ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យមួយចំនួនដូចជា៖ លក្ខណៈម៉ដ្ឋ គ្រើម ពណ៌ ជម្រៅស្រទាប់ដី វត្តមាន ឬអវត្តមាននៃស្រទាប់បំណែកក្រួសល្អិត និងស្រទាប់រឹង។ ប្រសិនបើមានលទ្ធភាពរកទិន្នន័យដីពីមន្ទីរពិសោធន៍អាចជាជំនួយដល់ការចាត់ថ្នាក់នៃដីដែរ តែមធ្យោបាយនេះសម្រាប់ជំនួយដល់អ្នកមានចំណេះដឹងអំពីដី ហើយមិនសូវមានបទពិសោធន៍ក្នុងការធ្វើចំណាត់ថ្នាក់ដីនៅវាលស្រែឲ្យបានទូលំទូលាយជាក្រុម ឬអនុក្រុម។

ចំណុចខ្លាំងរបស់ប្រព័ន្ធចំណាត់ថ្នាក់នេះ គឺជាភាពងាយរបស់វាក្នុងការប្រើប្រាស់ ដែលគេអាចធ្វើចំណាត់ថ្នាក់ដីនៅតាមបណ្តាតំបន់មួយចំនួនបានដោយឆាប់រហ័ស និងងាយស្រួល។ ទោះបីជាយ៉ាងណាក៏ដោយ ការពឹងពាក់លើលក្ខណៈវិនិច្ឆ័យខាងលើនេះ អាចបណ្តាលឲ្យមានការលំបាកខ្លះនៅក្នុងការធ្វើចំណាត់ថ្នាក់ដីនៅតំបន់ជាក់លាក់ណាមួយ ជាពិសេស ប្រសិនបើចំណាត់ថ្នាក់ដីធ្វើឡើងនៅព្រំប្រទល់រវាងក្រុមដីពីរផ្សេងគ្នា។ ដូច្នេះការធ្វើចំណាត់ថ្នាក់នៅក្នុងតំបន់ណាមួយ គួរតែត្រូវពឹងផ្អែកលើការអង្កេតច្រើនដងនៅតាមទីកន្លែងផ្សេងគ្នានៅក្នុងតំបន់សិក្សានោះ។

## ២.២ ចំនុចគួរយល់ដឹងក្នុងការធ្វើចំណាត់ថ្នាក់ដីតាមបែបក្សេត្រវិទ្យា

### *២.២.១ ភូមិសណ្ឋានវិទ្យានៃដីដាំដុះដំណាំស្រូវ*

គេអាចចែកតំបន់ដាំដុះដំណាំស្រូវនៅប្រទេសកម្ពុជា ជាបីតំបន់យ៉ាងងាយយល់តាមលក្ខណៈរូបសាស្ត្រដូចខាងក្រោម៖

- ដីដែលវិវត្តន៍នៅលើវាលទំនាបនៃល្បាប់ចាស់។
- ដីដែលវិវត្តន៍ទាំងស្រុងពីថ្មមេនៅខាងក្រោម។
- ដីដែលវិវត្តន៍នៅលើវាលទំនាបលិចទឹកទន្លេ ឬបឹងដែលទទួលកំណរដីល្បាប់ជារៀងរាល់ឆ្នាំ។

**តារាងទី១៖ ក្រុមដីសំខាន់ៗសម្រាប់ផលិតកម្មដំណាំស្រូវនៅកម្ពុជា**

| សណ្ឋានដី / ក្រុមដី | ផ្ទៃដី (%) |
|---|---|
| *សណ្ឋានដីដែលវិវត្តនៅលើវាលទំនាបនៃល្បាប់ចាស់* | |
| ក្រុមដី ព្រៃខ្មែរ | ១១ |
| ក្រុមដី ប្រទះឡាង | ២៨ |
| ក្រុមដី បាកាន | ១៣ |
| ក្រុមដី គោកត្រប់ | ៥ |
| ក្រុមដី ទួលសំរោង | ១០ |
| *សណ្ឋានដីដែលវិវត្តទាំងស្រុងពីថ្មមេនៅខាងក្រោម* | |
| ក្រុមដី ឡាបានសៀក | ១ |
| ក្រុមដី កំពង់សៀម | ២ |
| *សណ្ឋានដីដែលលិចទឹកសកម្ម* | |
| ក្រុមដី កៀនស្វាយ | ២ |
| ក្រុមដី ក្បាលពោធិ | ១៣ |
| ក្រុមដី ក្រគរ | ១៥ |

*ប្រភព៖ White et al., 1997*

Cambodian Agricultural Research and Development Institute (CARDI)

នៅក្នុងការអនុវត្តជាក់ស្តែងសម្រាប់ធ្វើចំណាត់ថ្នាក់ដីនៅប្រទេសកម្ពុជា គេប្រើប្រាស់សណ្ឋានដីចំនួនប្រាំ ដូចខាងក្រោម៖

- ដីស្ថិតនៅតំបន់លិចទឹកទន្លេ ព្រែក ស្ទឹង ឬបឹង យ៉ាងតិចរយៈពេល ៣ ខែ ឬក៏យូរជាងនេះ ហើយវាត្រូវលិចទឹក ៤ ឆ្នាំយ៉ាងតិច ក្នុងរយៈពេល ៥ ឆ្នាំ។
- ដីស្ថិតនៅតំបន់ចង្កេះភ្នំ ឬជើងភ្នំ។
- ដីស្ថិតនៅច្រាំងទន្លេ ឬស្ថិតនៅតំបន់ក្បែរខ្នងជម្រាលច្រាំងទន្លេ។
- ដីស្ថិតនៅតំបន់ដែលមានសណ្ឋានខ្ពស់ទាបមិនរាបស្មើ។
- ដីស្ថិតនៅតំបន់វាលរាបធំស្មើ។

**តារាងទី ២៖ លក្ខណសម្បត្តិគីមីនៃដីដាំដុះដំណាំស្រូវសំខាន់ៗនៅកម្ពុជា**

| លក្ខណៈគីមី | ព្រៃខ្មែរ | ប្រទះឡាង | បាកាន | គោកត្រប់ | ទូលសំរោង | កៀនស្វាយ | ក្រគរ / ក្បាលពោធិ |
|---|---|---|---|---|---|---|---|
| pH | ៥,៦ | ៥,៩ | ៥,៨ | ៥,១ | ៥,៥ | ៥,៩ | ៥,៩ |
| អាសូត (N), % | ០,០៥ | ០,០៣ | ០,០៦ | ០,១១ | ០,០៩ | ០,១០ | ០,១០ |
| ផូស្វ័រ (P), mg/kg | ១,៣ | ០,៤ | ១,០ | ២,៦ | ៣,១ | ៧,៥ | ៤,៦ |
| ប៉ូតាស្យូម (K), meq/100g | ០,០២ | ០,០៣ | ០,០៧ | ០,០៦ | ០,១៦ | ០,១៨ | ០,១៩ |
| កាបោនសរីរាង្គ, % | ០,៤៧ | ០,២៩ | ០,៦៦ | ១,០៩ | ០,៨៨ | ០,៩០ | ០,៩១ |

*ប្រភព៖ White et al., 1997*

### *២.២.២ ក្រុមដី*

ក្រុមដីត្រូវកំណត់ទៅតាមឯកតាដីដែលស្រដៀងគ្នាតាមលក្ខណៈរូបសាស្ត្រ ហើយកើតឡើងនៅទីតាំងមួយដូចគ្នា។ ឧទាហរណ៍៖ ដីឥដ្ឋពណ៌ខ្មៅប្រេះក្រហែងដែលកើតឡើងនៅលើដីល្បាប់ចាស់ ត្រូវធ្វើចំណាត់ថ្នាក់ឲ្យដាច់ដោយឡែកពីដីឥដ្ឋពណ៌ខ្មៅប្រេះក្រហែងដែលកើតនៅលើវាលទំនាបលិចទឹក។ ដីទាំងអស់ដែលមានស្រទាប់ខ្សាច់ជ្រៅដូចៗគ្នា ដែលកើតឡើងនៅលើដីល្បាប់សំណឹកជំនន់ចាស់ ត្រូវចាត់ថ្នាក់ក្នុងក្រុមជាមួយគ្នា។ លក្ខណៈវិនិច្ឆ័យដ៏ទូលាយនេះបានសន្មត់ទុកជាមុននូវសម្ព័ន្ធភាពមួយរវាងទីតាំងនៃឋានលេខា និងរូបសាស្ត្រជាមួយដំណើរកំណរកំណើតដី។

ក្រុមដីនីមួយៗ គេដាក់ឈ្មោះដោយកំណត់តាមទស្សនៈកណ្តាលមួយ ដែលគ្រាន់តែសម្គាល់លើលក្ខណៈសំខាន់ៗនៃក្រុមនោះ។ ការកកើតនៃដីត្រូវពិពណ៌នាដោយអនុលោមទៅតាមការពិពណ៌នាជាទូទៅមួយ អំពីលក្ខណៈរូបសាស្ត្ររបស់ក្រុមដីនោះ។

### *២.២.៣ អនុក្រុមដី*

អនុក្រុមដីចែកបន្តពីក្រុមដី។ អនុក្រុមទាំងនេះត្រូវកំណត់ជាចម្បងនៅលើលក្ខណៈសម្បត្តិនៃដីដែលមានសារៈសំខាន់ចំពោះផលិតកម្មដំណាំស្រូវ។ បទពិសោធន៍ និងជំនាញឯកទេសក្នុងមូលដ្ឋានមានសារៈសំខាន់ក្នុងការកំណត់ចំនួន និងប្រភេទរបស់អនុក្រុមដែលមាននៅក្នុងក្រុមនីមួយៗ។ ការកំណត់ថ្នាក់សម្រាប់អនុក្រុមត្រូវពឹងផ្អែកលើទិន្នន័យដែលទទួលបានមកពីឯកសារវិទ្យាសាស្ត្រ។

Cambodian Agricultural Research and Development Institute (CARDI)

### ២.២.៤ ចំណាត់ថ្នាក់តាមកម្រិតជីជាតិ

**ចំណាត់**ថ្នាក់តាមកម្រិតជីជាតិ ជាប្រព័ន្ធបច្ចេកទេសមួយសម្រាប់ចាត់ក្រុមដីទៅតាមប្រភេទបញ្ហា ដែលវាផ្តល់ចំពោះការគ្រប់គ្រងតាមបែបក្សេត្រវិទ្យា។ ចំណាត់ថ្នាក់តាមកម្រិតជីជាតិ អាចកំណត់បានដោយការធ្វើពិសោធន៍ស្រាវជ្រាវ តាមដានលើប្រសិទ្ធភាពនៃការគ្រប់គ្រងដំណាំ។ ចំពោះប្រភេទដីណាមួយក៏ដោយចំណាត់ថ្នាក់នឹងកំណត់ជាលេខកូដ ដែលមានដូចនៅក្នុងតារាងទី១។ ប្រព័ន្ធចំណាត់ថ្នាក់បែបនេះធ្វើឡើងសម្រាប់អ្នកស្រាវជ្រាវដែលមានចំណេះដឹងគ្រឹះអំពីដីប៉ុណ្ណោះ។

**តារាងទី ៣៖ ក្រុមដី អនុក្រុមដី ចំណាត់ថ្នាក់តាមកម្រិតដី**

| ក្រុមដី | *អនុក្រុមដី* | ចំណាត់ថ្នាក់តាមកម្រិតជីជាតិ** |
|---|---|---|
| ព្រៃខ្មែរ | *អនុក្រុមខ្សាច់គ្រើម*<br>*អនុក្រុមខ្សាច់ម៉ត់* | ខ្សត់ធាតុ N P K មានជម្រាបទឹកខ្លាំង សំណើមទាប pH=5-6 |
| ប្រទះឡាង | *អនុក្រុមរាក់*<br>*អនុក្រុមដីល្បាយស្រទាប់ក្រោម*<br>*អនុក្រុមដីឥដ្ឋស្រទាប់ក្រោម* | ខ្សត់ធាតុ N P K មានជ្រាបខ្លាំង ផ្ទុកទឹកទាប pH=5-6<br>ខ្សត់ធាតុ N P K មានជម្រាបទឹកមធ្យម pH=5-6<br>ខ្សត់ធាតុ N P K ផ្ទុកទឹកល្អប្រសើរ pH=5-6 |
| ឡាបានសៀក | *អនុក្រុមគ្មានក្រួស (មិនមែនផេត្រូហ្វៀរិច)*<br>*អនុក្រុមមានក្រួស (ផេត្រូហ្វៀរិច)* | ខ្សត់ធាតុ K ជម្រាបទឹកខ្សោយ សមត្ថភាពផ្ទុកទឹកខ្ពស់ អាចកង្វះធាតុ P, Zn |
| អូរ៉ាំង | *អូរ៉ាំង* | ខ្សត់ធាតុ N P K សមត្ថភាពផ្ទុកទឹកល្អ |
| ក្រគរ | *អនុក្រុមបែកក្រហែង*<br>*អនុក្រុមមិនបែកក្រហែង* | ជម្រាបទឹកពីខ្សោយ-មធ្យម សមត្ថភាពផ្ទុកទឹកខ្ពស់ |
| បាកាន | *បាកាន* | ខ្សត់ធាតុ N P K សមត្ថភាពផ្ទុកទឹកល្អ ជ្រាបទឹកមធ្យម |
| ក្បាលពោធិ | *អនុក្រុមស្បូនិច*<br>*(pH ស្រទាប់ក្រោមតូចជាង ៤,៥)*<br>*អនុក្រុមមិនស្បូនិច*<br>*(pH ស្រទាប់ក្រោមធំជាង ៤,៥)* | ជម្រាបទឹកខ្សោយ សមត្ថភាពផ្ទុកទឹកខ្ពស់ ដីអាស៊ីតស៊ុលផាត ខ្សត់ធាតុ Zn អាចពុល Fe, S, Al<br>ជម្រាបទឹកខ្សោយ សមត្ថភាពផ្ទុកទឹកខ្ពស់ ដីអាស៊ីតស៊ុលផាត ខ្សត់ធាតុ Zn |
| កៀនស្វាយ | *កៀនស្វាយ* | ជម្រាបទឹកមធ្យម សមត្ថភាពផ្ទុកទឹកមធ្យម អាចកង្វះធាតុផូស្វ័រ |
| ទួលសំរោង | *អនុក្រុមពណ៌ខ្មៅ*<br>*អនុក្រុមពណ៌ប្រផេះ* | ខ្សត់ N និង P ជម្រាបទឹកខ្សោយ សមត្ថភាពផ្ទុកទឹកខ្ពស់ |
| គោកត្រប់ | *អនុក្រុមមានជីជាតិ*<br>*អនុក្រុមគ្មានជីជាតិ* | ជ្រាបទឹកមធ្យម សមត្ថភាពផ្ទុកទឹកមធ្យម<br>ខ្សត់ P, K, Zn ជម្រាបទឹកខ្សោយ សមត្ថភាពផ្ទុកទឹកខ្ពស់ |
| កំពង់សៀម | *អនុក្រុមមានក្រួស*<br>*អនុក្រុមគ្មានក្រួស* | ខ្សត់ Zn ជម្រាបទឹកខ្សោយ សមត្ថភាពផ្ទុកទឹកខ្ពស់ |

***ចំណាត់ថ្នាក់តាមកម្រិតជីជាតិនេះមានការបកស្រាយលម្អិតនៅក្នុងសៀវភៅ "ដីប្រើប្រាស់សម្រាប់ផលិតកម្មដំណាំស្រូវនៅកម្ពុជា" ឆ្នាំ ១៩៩៧។*

Cambodian Agricultural Research and Development Institute (CARDI)

### ២.៣ ការកំណត់លក្ខណៈរូបសាស្ត្រនៃដី

**ដើម្បី**ធ្វើចំណាត់ថ្នាក់ដីសម្រាប់ដាំដុះស្រូវបាន លោកអ្នកត្រូវប្រើប្រាស់ TIP "ចំណាត់ថ្នាក់ដីសម្រាប់ផលិតកម្មដំណាំស្រូវនៅកម្ពុជា" នឹងត្រូវមានការយល់ដឹងអំពីលក្ខណៈរូបសាស្ត្រសំខាន់ៗនៃដី ដូចខាងក្រោម៖

### *២.៣.១ ការកំណត់ស្រទាប់ដី*

**ការ**កំណត់ស្រទាប់ដី ចាំបាច់ត្រូវជីករណ្ដៅមួយឲ្យបានជម្រៅ ៥០ ស.ម រួចគេធ្វើការវាស់ដោយគិតចាប់ពីផ្ទៃដីផ្នែកខាងលើ។ ស្រទាប់ដីចែកចេញជាពីរស្រទាប់គឺ ស្រទាប់ទី១ (ស្រទាប់ខាងលើ) ចាប់ពី ០ ទៅ ២០ ស.ម និងស្រទាប់ទី២ (ស្រទាប់ក្រោម) ជម្រៅដីចាប់ពី ២០ ទៅ ៥០ ស.ម។ ការកំណត់ស្រទាប់ដីពុំចាំបាច់គិតអំពី ពណ៌ និងវាយនភាពដីទេ។

### *២.៣.២ ការកំណត់វាយនភាពដី*

**នៅ**តាមវាលស្រែ វាយនភាពដីត្រូវបានកំណត់ដោយការឈ្លីដី (ស្ទាប/ច្របាច់មើល) តាមរបៀបដូចខាងក្រោម៖

ក. យកសំណាកដីល្មម ដាក់ទៅលើបាតដៃ (ដីកន្លះក្ដាប់)។

ខ. ដកយកចេញនូវរបស់ផ្សេងៗ ដូចជាក្រួស ឬស ស្លឹក គ្រាប់រុក្ខជាតិ និងសត្វល្អិតឲ្យបានស្អាតល្អ។

គ. ផ្សើមសំណាកដីជាមួយនឹងទឹកបន្តិចម្ដងៗ ពេលជាមួយគ្នានោះច្របាច់លញ់ដីរហូតដល់វាចាប់ផ្ដើមស្អិតទៅនឹងម្រាមដៃរបស់អ្នក នេះហៅថាចំណុចស្អិត។

#### ***វាយនភាពដីនឹងកំណត់សំគាល់ដូចខាងក្រោម៖***

**ដីខ្សាច់៖** ពុំមាន ឬមានជាតិស្អិតតិចតួច ឬជាដុំមូលគ្រាតអាចមានទម្រង់ដែលងាយបែកនៅពេលគេច្របាច់ ឬអាចបង្កើតចេញជាដីអង្កត់វែង និងអង្កត់មិនមានទម្រង់ស្មើសាច់ល្អហើយមានស្នាមប្រេះ និងមើលឃើញថា ដីមានខ្សាច់ច្រើន និងមិនស្អិតទេ។

**ដីល្បាយ៖** ដីអាចលញ់បានជារាងកូនឃ្លី ឬរាងស៊ីឡាំងដែលមានជាតិស្អិត កូនឃ្លី ឬស៊ីឡាំងនេះអាចលញ់បានជាសសៃ (ប្រវែងប្រហែល ១៣ ស.ម អង្កត់ផ្ចិត ០,៦ ស.ម) ហើយមិនស្អិតជាប់ដៃឡើយ ហើយអាចបត់ជារាងអក្សរអ៊ុយ (U) ឬជារង្វង់ ហើយរាងជាអក្សរ U និងរង្វង់នេះ មានស្នាមប្រេះ ជួនកាលដីនេះស្អិតដៃតិចៗ និងមានសភាពរអិលដូចស្ទាបសូត្រ តែវាអាចមានជាតិខ្សាច់គ្រើមៗតិចតួចដែរ។

**ដីឥដ្ឋ៖** ដីអាចលញ់បានជារាងគ្រាប់ឃ្លីដែលរលោង និងស្អិត ហើយដីមានសភាពស្អិតរមួតជាប់ម្រាមដៃ ដែលអាចលញ់បានជាសសៃវែងឆ្មារ និងបត់បានជារាងរង្វង់ដោយគ្មានស្នាមប្រេះឡើយ ឯដីមានសភាពរលើបពេលសើម និងវាមានសភាពស្អិតនៅពេលសើម និងមានសភាពរលើប ដូចក្រណាត់សូត្រ ឬរអិល តែពេលខ្លះក៏អាចមានកម្ទេចខ្សាច់ ២-៣ គ្រាប់ដែរ។



*ការកំណត់វាយនភាពនៃដី*

### *២.៣.៣ កាកំណត់ពណ៌ដី*

**ពណ៌**នៃដីផ្សំពីធាតុបង្កពីរយ៉ាងគឺ ពណ៌សាច់ដី (ជាតួសំខាន់នៃដី) និងស្នាមចម្រុះពណ៌ (ខុសពីពណ៌នៃសាច់ដី)។ ក្នុងករណីខ្លះ ពណ៌ចម្រុះមានច្រើនសណ្ឋានណាស់ ដែលវាហាក់ដូចជាលប់លើពណ៌របស់សាច់ដី។ តែទោះជា

Cambodian Agricultural Research and Development Institute (CARDI)

យ៉ាងណាក៏ដោយគួរចងចាំថា ពណ៌ដីអាស្រ័យលើពណ៌នៃសាច់ដីប៉ុណ្ណោះ។ ពណ៌ដែលមាននៅក្នុងឯកសារនេះមានចំនួន ១៥ ពណ៌ ប្រើសម្រាប់ធ្វើការប្រៀបធៀបពណ៌ដីនៅកម្ពុជា។ ជាទូទៅពណ៌ទាំងនេះវាពុំដូចទាំងស្រុងនោះទេ ដូច្នេះ យើងត្រូវជ្រើសរើសយកពណ៌ដែលស្រដៀងប៉ុណ្ណោះ។ ការផ្ទៀងផ្ទាត់ពណ៌ ត្រូវធ្វើជាក្រុមដែលមានសមាជិកចាប់ពី ៣-៥ នាក់។ នៅពេលធ្វើការកំណត់ពណ៌ ត្រូវដាក់សំណាកដីឲ្យចំពន្លឺថ្ងៃ និងមិនត្រូវពាក់វ៉ែនតាការពារភ្នែកទេ។



**ផ្ទាំងគំរូពណ៌សម្រាប់ការធ្វើចំណាត់ថ្នាក់ដីនៅកម្ពុជាតាមបែបក្សេត្រវិទ្យា**




### *២.៣.៤ ការកំណត់ស្រទាប់រឹង*

**ស្រទាប់រឹង** ជាស្រទាប់ក្នុងដីដែលណែនខ្លាំងមានសមាសធាតុដីឥដ្ឋច្រើន ហើយមានលក្ខណៈខុសៗគ្នា។ ក៏ប៉ុន្តែនៅក្នុង TIP នេះ យើងប្រើសំដៅលើតែស្រទាប់ហាប់ណែនប៉ុណ្ណោះ។ ស្រទាប់រឹងក្នុងដីនេះអាចជាស្រទាប់ក្ដួរ ឬស្រទាប់ក្រួសដែលរឹង។ ស្រទាប់ដីនេះវារាំងស្ទះដល់ការជ្រាបទឹក ឬរាំងស្ទះដល់ការចាក់ឫសរបស់ដំណាំស្រូវ។ **ដើម្បី**កំណត់ថា ស្រែមួយមានស្រទាប់រឹង ឬគ្មាន លោកអ្នកត្រូវយកឧបករណ៍ដែលមានចុងស្រួចដូចជាកាំបិត ឬកំណាត់ឈើចាក់ទៅក្នុងដីសន្សឹមៗ។ ប្រសិនបើមានការប្រែប្រួល គួរកត់សម្គាល់ណាមួយដោយកាំបិត ឬអង្កត់ឈើដែលចាក់ចូលក្នុងដី ហាក់ដូចជាចាក់លើអ្វីមួយដែលរឹងជាងធម្មតាប្រហែល ២-៣ ស.ម រួចក៏ទន់ធម្មតាវិញ នោះគេចាត់ទុកថាមានស្រទាប់រឹង។

### *២.៣.៥ ការកំណត់ភាពក្រហែងដី*

ក្រហែងដីភាគច្រើនកើតឡើងនៅលើដីដែលមានវាយនភាពជាដីឥដ្ឋ ឬដីល្បាយ ចំពោះដីខ្សាច់ពុំមានក្រហែងទេ។ ជាទូទៅយើងអាចពិនិត្យឃើញក្រហែងដីនៅពេលដីស្ងួត។ ការកំណត់ក្រហែងដីយើងធ្វើឡើងដោយការវាស់វែងនូវទំហំ និងជម្រៅនៃក្រហែង។

### *២.៣.៦ ថ្មកំបោរ និងថ្មបាសាល់*

មុននឹងពិនិត្យថ្មឲ្យបានល្អ លោកអ្នកត្រូវបំបែកវាជាពីរ ហើយត្រូវពិនិត្យលើផ្ទៃថ្មីដែលទើបនឹងបែកនោះ។

- *ថ្មកំបោរ៖* ក្នុងប្រទេសកម្ពុជា ជាសិលាកំណក។ វាជាដុំថ្មតូច ឬធំ ទំហំប្រែប្រួលពី ១ ស.ម ទៅ ១០ ស.ម។ វាអាចមានពណ៌ប្រផេះ ស ជួនកាលពណ៌ត្នោត។ ថ្មនេះអាចមានទំហំ ១-៥ ម.ម មានទម្រង់ជាម៉្យាម៉ដ្ឋ ហើយអាចកូតដាច់ដោយលោហៈ និងរលាយនៅក្នុងអាស៊ីតក្លរីឌ្រីចត្រជាក់។

- *ថ្មបាសាល់៖* នៅប្រទេសកម្ពុជា ថ្មបាសាល់មានពីរប្រភេទ ដែលប្រភេទទី១ មានពណ៌ប្រផេះ ឬប្រផេះចាស់។ វាមានសភាពរឹងមិនអាចកូតដាច់ដោយលោហៈឡើយ។ ទម្រង់វាជាគ្រីស្តាល់ម៉ដ្ឋរឹង។ ប្រភេទទី២ មានពណ៌ដូចខាងលើដែរ តែទ្រង់ទ្រាយវាមិនសូវរឹង និងមានប្រហោងច្រើន វាងាយកូតដាច់ដោយលោហៈណាស់។ វាមានលក្ខណៈជាដុំថ្មធំៗ ឬក្រួសតូចៗ។

## ៣. វិធីសាស្ត្រធ្វើចំណាត់ថ្នាក់ដីសម្រាប់ដំណាំស្រូវ

ការធ្វើចំណាត់ថ្នាក់ដីនៅប្រទេសកម្ពុជា ជាវិធីសាស្ត្រសាមញ្ញ ដែលអាចធ្វើនៅលើវាលស្រែដោយពុំចាំបាច់ពឹងផ្អែកលើទិន្នន័យនៃការវិភាគដីនៅមន្ទីរពិសោធន៍ឡើយ។ គួរចាំថា ការធ្វើចំណាត់ថ្នាក់ដីត្រូវធ្វើឡើងឲ្យបានច្រើនកន្លែងប្រសើរជាងការចាត់ថ្នាក់ដីដោយពឹងផ្អែកទៅលើការពិពណ៌នាអំពីប្រូហ្វីលដីតែមួយកន្លែងនៅក្នុងតំបន់មួយ។

### ៣.១ ដំណើរការសម្រាប់ការធ្វើចំណាត់ថ្នាក់ដី

ការធ្វើអត្តសញ្ញាណក្រុមដី និងអនុក្រុមដីចែកចេញជាពីរដំណាក់កាល ដែលជំហានដំបូងដោយប្រើសំនួរគន្លឹះ។ សំនួរគន្លឹះទាំងនេះផ្តល់ចំណាត់ថ្នាក់ប្រហាក់ប្រហែលមួយ។ ជំហានបន្ទាប់ ធ្វើការពិពណ៌នាប្រូហ្វីលដី ការពិពណ៌នានេះធ្វើឡើងដើម្បីកំណត់ស្រទាប់ដី វាយនភាពរបស់ដី ពណ៌ដីស្រទាប់រឹង និងវត្តមាននៃថ្ម ឬក្រួស។ គួរមានវត្តមាននៃកសិករ ឬអ្នកប្រើប្រាស់ដីដែលកំពុងធ្វើចំណាត់ថ្នាក់ ដើម្បីផ្តល់ព័ត៌មានបន្ថែមក្នុងករណីចាំបាច់ខ្លះ។



**ជំហានទី១៖ ការធ្វើចំណាត់ថ្នាក់ដីដោយប្រើសំនួរគន្លឹះ**

- កំណត់ទីតាំង ឬសណ្ឋានដីដែលចង់ធ្វើចំណាត់ថ្នាក់ដីនេះ ថាតើវាស្ថិតនៅសណ្ឋានដីណាមួយក្នុងចំណោមសណ្ឋានដីទាំងប្រាំ។
- កំណត់ក្រុម ឬអនុក្រុមដីដោយប្រើសំនួរគន្លឹះ រួចឆ្លើយសំនួរដែលបានសរសេរនៅក្នុងតារាង "សំនួរគន្លឹះសម្រាប់ដីដាំដុះដំណាំស្រូវសំខាន់" ទៅតាមសណ្ឋានដីនីមួយៗ។
- ធ្វើការប្រៀបធៀបរវាងក្រុម ឬអនុក្រុមដែលផ្តល់ដោយសំនួរគន្លឹះជាមួយការពិពណ៌នាទូទៅអំពីក្រុមដី។

**ជំហានទី២៖ ការពិពណ៌នាប្រូហ្វីលដី**

- ការជ្រើសរើសទីកន្លែងសម្រាប់ធ្វើការពិពណ៌នាប្រូហ្វីលដី ត្រូវធ្វើនៅទីកន្លែងណាដែលមានលក្ខណៈ

Cambodian Agricultural Research and Development Institute (CARDI)

តំណាងឲ្យដីនៅក្នុងស្រែទាំងមូល។

- ត្រូវជីករណ្តៅដែលមានជម្រៅ ០,៥ ម បណ្តោយ ០,៥ ម និងទទឹង ០,៥ ម។ ជាទូទៅផ្ទៃដី ១ ហិកតា ត្រូវជីករណ្តៅចំនួន ១ រណ្តៅ។
- ការយកសំណាកដីតាមស្រទាប់នីមួយៗ យើងត្រូវយកចំនួន ៣ សំណាករង ក្នុងមួយស្រទាប់ ដែលសំណាក់រងនីមួយៗត្រូវឲ្យមានភាពជាតំណាងឲ្យដីស្រទាប់នោះ។ បន្ទាប់មកត្រូវយកសំណាករងទាំង ៣ នេះ ច្របល់បញ្ចូលគ្នា។
- យកសំណាកដែលបានច្របល់ចូលគ្នាទាំងនេះ ទៅធ្វើការផ្ទៀងផ្ទាត់ពណ៌ជាមួយតារាងណែនាំអំពីពណ៌ដី និងកំណត់វាយនភាពដី។
- ត្រូវកត់ត្រាព័ត៌មាន ដូចជាវាយនភាពដី ពណ៌ដី វត្តមានស្រទាប់រឹង និងវត្តមានថ្ម ឬក្រួស ឲ្យបានច្បាស់ទៅតាមស្រទាប់នីមួយៗ។
- យកព័ត៌មានទាំងនេះទៅផ្ទៀងផ្ទាត់ជាមួយការពិពណ៌នាអំពីក្រុមដី ឬអនុក្រុមដី ដើម្បីធ្វើអត្តសញ្ញាណក្រុមដី ឬអនុក្រុមដីទាំងនោះ។

### ៣.២ តម្រូវការសម្ភារៈ និងឧបករណ៍

១- សៀវភៅ TIP "ចំណាត់ថ្នាក់ដីសម្រាប់ផលិតកម្មដំណាំស្រូវនៅប្រទេសកម្ពុជា"
២- តារាងណែនាំអំពីពណ៌ដី
៣- សៀវភៅ "ដីប្រើប្រាស់ដីសម្រាប់ផលិតកម្មស្រូវនៅកម្ពុជា"
៤- ផែនទីដីប្រើប្រាស់សម្រាប់ផលិតកម្មដំណាំស្រូវនៅប្រទេសកម្ពុជា
៥- ឧបករណ៍វាស់ pH របស់ដី (pH meter/pH test kit)
៦- ចបកាប់
៧- កាំបិតចុងស្រួច
៨- ម៉ែត្រ ឬបន្ទាត់
៩- ឈើសម្រួចចុងដែលមានប្រវែង ១០ ស.ម ចំនួន ២-៣ ដើម។
១០- ធុងដាក់ទឹក
១១- ដបទឹកសម្រាប់បាញ់លាងសម្អាតឧបករណ៍ផ្សេងៗ
១២- ទឹកសម្រាប់សម្អាតសម្ភារៈ
១៣- ថង់សម្រាប់ច្រកសំណាកដី
១៤- ប៊ិក និងហ្វឺត
១៥- សៀវភៅសម្រាប់កត់ត្រា

Cambodian Agricultural Research and Development Institute (CARDI)

### ៣.៣ សំនួរគន្លឹះសម្រាប់ចំណាត់ថ្នាក់ដីដាំដុះដំណាំស្រូវ







Cambodian Agricultural Research and Development Institute (CARDI)

**សំនួរគន្លឹះទី ៣៖** ដីស្ថិតនៅតំបន់ច្រាំងទន្លេ ឬស្ថិតនៅតំបន់ក្បែរខ្នងជម្រាលច្រាំងទន្លេ




**សំនួរគន្លឹះទី ៤៖** ដីស្ថិតនៅតំបន់ដែលមានសណ្ឋានខ្ពស់ទាបៗមិនរាបស្មើ




Cambodian Agricultural Research and Development Institute (CARDI)

៥-មានក្រហែងជ្រៅជាង ៣-៤ ស.ម ពេលណាដីស្ងួត?
- បាទ → ដីមិនទាន់បានធ្វើអត្តសញ្ញាណ
- បាទ ↓

៦-ដីស្រទាប់លើមានពណ៌ត្នោត?
- បាទ → ក្រុមទួលសំពោង អនុក្រុមពណ៌ត្នោត
- ទេ ↓

៧-ដីស្រទាប់លើមានពណ៌ប្រផេះ?
- បាទ → ក្រុមទួលសំពោង អនុក្រុមពណ៌ប្រផេះ
- ទេ → ដីមិនទាន់បានធ្វើអត្តសញ្ញាណ

៨-ស្រទាប់លើមានពណ៌ប្រផេះក្រមៅខ្លាំងទៅត្នោតក្រមៅខ្លាំង ឬខ្មៅ?
- បាទ → មើលលេខ ១២
- បាទ ↓

៩-មានស្នាមបែកក្រហែងពេលណាដីស្ងួត?
- ទេ → ក្រុមបាកាន អនុក្រុមបាកាន
- បាទ ↓

១០-មានបែកក្រហែងមិនលើសពី ៣-៤ ស.ម
- បាទ → ក្រុមបាកាន អនុក្រុមបាកាន
- ទេ ↓

១១-មានបែកក្រហែងជ្រៅជាង ៣-៤ ស.ម ពេលណាដីស្ងួត?
- បាទ → មើលលេខ ៦
- ទេ → ដីមិនទាន់បានធ្វើអត្តសញ្ញាណ

១២-ក្នុងស្រទាប់ដីមានវត្តមានថ្មបាសាល់ ថ្មកំបោរ ឬក្រួស?
- បាទ → មើលលេខ ១៧
- បាទ ↓

១៣-មានកូនភ្នំនៅក្បែរ ហើយមានវត្តមានដីក្រហមឡាបានសៀក?
- បាទ → មើលលេខ ១៧
- បាទ ↓

១៤-ប្រសិនបើមិនដាក់ដីលើស្រែកសិករ ទិន្នផលបាន ១,២ តោន/ហិកតា ឬតិចជាង?
- បាទ → ក្រុមគោកត្រប់ អនុក្រុមខ្សត់ជីជាតិ
- ទេ ↓

១៥-ប្រសិនបើមិនដាក់ដីលើស្រែកសិករ ទិន្នផលបានខ្ពស់ជាង ១,២ តោន/ហិកតា?
- បាទ → ក្រុមគោកត្រប់ អនុក្រុមមានជីជាតិ

Cambodian Agricultural Research and Development Institute (CARDI)

**១៦-ដីមានពណ៌ប្រផេះចាស់ទៅខ្មៅ?**
- ទេ → មើលលេខ ២០
- បាទ ↓

**១៧-ដីមានបែកក្រហែងជម្រៅ ៣-៤ ស.ម ឬជ្រៅជាងពេលដីស្ងួត?**
- ទេ → ដីពុំទាន់បានធ្វើអត្តសញ្ញាណ
- បាទ ↓

**១៨-ក្រួសផ្សេងៗមាននៅក្នុងស្រទាប់ដី?**
- បាទ → ក្រុមកំពង់សៀម អនុក្រុមមានក្រួស
- ទេ ↓

**១៩-ពុំមានក្រួសនៅក្នុងស្រទាប់ដីទេ?**
- បាទ → ក្រុមកំពង់សៀម អនុក្រុមគ្មានក្រួស

**២០-ដីលើមានពណ៌ក្រហមទៅត្នោត ហើយមានសភាពគ្រាប់ៗ?**
- ទេ → ដីមិនទាន់បានធ្វើអត្តសញ្ញាណ
- បាទ ↓

**២១-ដីមានស្រទាប់ថ្មដែករឹងក្នុងជម្រៅ ប្រមាណ ៥០ ស.ម?**
- បាទ → ក្រុមឡាបានសៀក អនុក្រុមផេត្រូហ្វៀរិច
- ទេ ↓

**២២-ដីពុំមានស្រទាប់រឹងជាឧបសគ្គចំពោះការលូតលាស់នៃឫសរុក្ខជាតិក្នុងជម្រៅ ៥០ ស.ម?**
- បាទ → ក្រុមឡាបានសៀក អនុក្រុមមិនមែនផេត្រូហ្វៀរិច

## សំនួរគន្លឹះទី ៥៖ ដីស្ថិតនៅតំបន់វាលរាបធំស្មើ

**១-ស្រទាប់ខាងលើជាខ្សាច់មានជម្រៅជ្រៅជាង ៥០ ស.ម?**
- បាទ → មើលលេខ ១៣
- ទេ ↓

**២-ដីស្រទាប់លើជាខ្សាច់ ស្រទាប់ក្រោមជាល្បាយ ឬដីឥដ្ឋ?**
- បាទ → មើលលេខ ១០
- ទេ ↓

**៣-ដីស្រទាប់លើ និងស្រទាប់ក្រោមជាល្បាយ ឬដីឥដ្ឋ?**
- ទេ → មើលលេខ ១៥
- បាទ ↓

**៤-ស្រទាប់ដីលើមានពណ៌ប្រផេះក្រមៅទៅត្នោតក្រមៅខ្លាំង ឬខ្មៅ?**
- បាទ → មើលលេខ ១៦
- ទេ ↓

Cambodian Agricultural Research and Development Institute (CARDI)




Cambodian Agricultural Research and Development Institute (CARDI)

**១៦**-ក្នុងស្រទាប់ដីមានវត្ថុមានថ្មបាសាល់ ថ្មកំបោរ ឬក្រួស?
- បាទ → មើលលេខ ២០
- ទេ ↓

**១៧**-មានកូនភ្នំនៅក្បែរហើយមានវត្ថុមានដី ក្រហមឡាបានសៀក?
- បាទ → មើលលេខ ២០
- ទេ ↓

**១៨**-ប្រសិនបើមិនដាក់ជីលើស្រែកសិករ ទិន្នផលបាន ១,២ តោន/ហិកតា ឬតិចជាង?
- បាទ → ក្រុមគោកត្រប់ អនុក្រុមខ្សត់ជីជាតិ
- ទេ ↓

**១៩**-ប្រសិនបើមិនដាក់ជីលើស្រែកសិករ ទិន្នផលបានខ្ពស់ជាង ១,២ តោន/ហិកតា?
- បាទ → ក្រុមគោកត្រប់ អនុក្រុមមានជីជាតិ

**២០**-ដីមានបែកក្រហែងជម្រៅ ៣-៤ ស.ម ឬជ្រៅជាងពេលដីស្ងួត?
- ទេ → ដីមិនទាន់បានធ្វើអត្តសញ្ញាណ
- បាទ ↓

**២១**-ក្រួសផ្សេងៗមាននៅក្នុងស្រទាប់ដី?
- បាទ → ក្រុមកំពង់សៀម អនុក្រុមមានក្រួស
- ទេ ↓

**២២**-ពុំមានក្រួសនៅក្នុងស្រទាប់ដីទេ?
- បាទ → ក្រុមកំពង់សៀម អនុក្រុមគ្មានក្រួស

Cambodian Agricultural Research and Development Institute (CARDI)

## ៤. ការពិពណ៌នាអំពីក្រុមដី

### ៤.១ ក្រុមដី ព្រៃខ្មែរ




ជាប្រភេទដីម្យ៉ាង ដែលកើតឡើងលើទំនាបល្បាប់ជំនន់ចាស់ ឬទំនាបល្បាប់ជំនន់ល្បាប់សំណឹក ដែលវាយភាពនៃប្រូហ្វីល មានលក្ខណៈជាខ្សាច់ជម្រៅជាង ៥០ ស.ម។ ដីប្រភេទនេះមានប្រមាណ ១១ ភាគរយ នៃដីដាំដុះស្រូវសរុប។ ដីនេះត្រូវបានគេបែងចែកជាពីអនុក្រុមខុសគ្នាៈ មួយគឺ អនុក្រុមខ្សាច់ម៉ដ្ឋ និងមួយទៀតអនុក្រុមខ្សាច់គ្រើម។ ក្រុមដីព្រៃខ្មែរលំបាកក្នុងការគ្រប់គ្រង សម្រាប់ផលិតកម្មដំណាំស្រូវ។ ដីនេះពុំសមស្របចំពោះការស្រោចស្រពទេ ហើយជីជាតិនៃដីក៏តិចដែរ។ តាមការពិសោធន៍នៅផ្ទះកញ្ចក់បង្ហាញថា ដីនេះកើតមាននូវកង្វះសារធាតុ N, P, K, S និង Mg។ មិនតែប៉ុណ្ណោះកម្រិតនៃសារធាតុសរីរាង្គទាប ហើយការគ្រប់គ្រងជីជាតិមានការលំបាក ដោយសារដីនេះងាយជ្រាបទឹក និងមានការលំបាកក្នុងការតម្រូវអាហារធាតុទៅនឹងសេចក្តីត្រូវការរបស់ដំណាំ។

### ៤.២ ក្រុមដី ប្រទះឡាង




ជាប្រភេទដីកើតឡើងលើទំនាបល្បាប់ជំនន់ចាស់ ឬទំនាបល្បាប់ជំនន់ជាល្បាប់សំណឹក ដែលមានខ្សាច់កម្រាស់តិចជាង ៤០ ស.ម ដីស្រទាប់ក្រោមមានវាយនភាពល្បាប់ ឬឥដ្ឋ។

ដីប្រភេទនេះជាដីដំណាំស្រូវទូទៅ និងមានប្រមាណ ២៨ ភាគរយ នៃតំបន់ដាំដុះសរុប។ ក្រុមដីប្រទះឡាងត្រូវបានគេធ្វើចំណាត់ថ្នាក់ជា ៣ អនុក្រុមផ្សេងគ្នា ដោយផ្អែកលើលក្ខណៈនៃដីស្រទាប់ក្រោម ដែលមានឥទ្ធិពលលើការចាក់ឫសរបស់ដំណាំ និងការជ្រាបទឹក។ អនុក្រុមទាំងនោះមានៈ អនុក្រុមរាក់ អនុក្រុមដីឥដ្ឋស្រទាប់ក្រោម និងអនុក្រុមដីល្បាយស្រទាប់ក្រោម។ ដីនេះមានការលំបាកក្នុងការគ្រប់គ្រងចំពោះផលិតកម្មដំណាំស្រូវ។ ប្រសិនបើរចនាសម្ព័ន្ធសម្រាប់ការស្រោចស្រព និងប្រើប្រាស់ទឹកអាចត្រូវបានប្រើក្នុងតម្លៃថោកនោះ គេសង្ឃឹមថានឹងទទួលទិន្នផលចំណេញ។

### ៤.៣ ក្រុមដី ឡាបានសៀក




ដីឡាបានសៀក កើតមាននៅតាមជើងភ្នំ ឬនៅលើភ្នំ ដែលមានដីពណ៌ក្រហម ផ្ទៃខាងលើមានវាយនភាពជាឥដ្ឋ មានទម្រង់ខ្ទេច ហើយស្រទាប់ក្រោមមានវាយនភាពជាឥដ្ឋដែរ។ ដីនេះមានតិចជាង ១ ភាគរយ នៃផ្ទៃដីដាំស្រូវសរុប។ ដីឡាបានសៀកមានជីជាតិមធ្យម កម្រិតនៃសារធាតុសរីរាង្គប្រែប្រួលពីមធ្យមទៅខ្ពស់ ហើយសមស្របទៅនឹងផលិតកម្មស្រូវចម្ការ។

ការពិសោធន៍នៅផ្ទះកញ្ចក់បានបង្ហាញថា ដីនេះខ្វះធាតុ N, P, K និង S នៅលើស្រែ។ ជាទូទៅក្រុមដីនេះ ជាដីដែលមានលក្ខណៈអាស៊ីតខ្សោយ តែវាយអាចមានលក្ខណៈជាដីអាល់កាឡាំងដែរ។

Cambodian Agricultural Research and Deve
(CARDI)

### ៤.៤ ក្រុមដី ក្រគរ



ដីក្រគរ ជាដីមានពណ៌ប្រផេះត្នោត ប៉ុន្តែមិនមែនប្រផេះក្រមៅ ឬត្នោតក្រមៅ ឬខ្មៅនោះទេ។ ដីក្រគរមានទម្រង់ជាដីល្បាប់ ឬដីឥដ្ឋនៅស្រទាប់ខាងលើ និងមានទម្រង់ជាដីខ្សាច់ ឬល្បាប់ ឬដីឥដ្ឋ នៅស្រទាប់ខាងក្រោម។ ដីប្រភេទនេះកើតមាននៅតំបន់ទំនាបលិចទឹកសកម្ម។ ដីក្រគរកើតមាននៅក្នុងគ្រប់ខេត្តដែលមានប្រមាណ ១៥ ភាគរយ នៃផ្ទៃដីដាំដុះស្រូវនៅកម្ពុជា។ ដីនេះត្រូវបានចែកជា ២ អនុក្រុម គឺអនុក្រុមមិនប្រេះក្រហែង និងអនុក្រុមប្រេះក្រហែង។ គេរំពឹងថាដីនេះនឹងត្រូវបានចាត់ថ្នាក់ជាអនុក្រុមបន្ត អាស្រ័យទៅនឹងការងារលម្អិតថែមទៀត។ ដីក្រគរមានសក្តានុពលភាពខ្ពស់ និងមានការឆ្លើយតបល្អទៅនិងការគ្រប់គ្រងកែច្នៃ។ ដីប្រភេទនេះមានអំណោយផលចំពោះការស្រោចស្រព ប្រសិនបើគេអាចគ្រប់គ្រងទឹកបានយ៉ាងមានប្រសិទ្ធភាពនោះ។ ការលូតលាស់របស់ឫសគ្មានព្រំដែនទេក្នុងដីនេះ។ ការពិសោធន៍នៅផ្ទះកញ្ចក់ និងនៅតាមស្រែបានបង្ហាញឲ្យឃើញថា ដីនេះឆ្លើយតបទៅនឹងការប្រើប្រាស់តែអាសូត និងផូស្វ័រ ប៉ុណ្ណោះ។ ដីនេះជាក្រុមដីដែលមានជីជាតិល្អ។




### ៤.៥ ក្រុមដី បាកាន

ដីបាកាន កើតឡើងនៅលើទំនាបល្បាប់ចាស់ និងល្បាប់ជំនន់ ឬល្បាប់។ ដីស្រទាប់លើជាល្បាយ ឬឥដ្ឋ ពុំមានវត្តមានក្រហែងទេ ឬបើមាន គឺមានតែនៅផ្ទៃដីលើវាក់ៗប៉ុណ្ណោះ។ ដីស្រទាប់ក្រោមជាដីល្បាយ ឬឥដ្ឋមានស្នាមចម្រុះ។

ក្រុមដីបាកានមានប្រហែល ១២ ភាគរយ នៃដីដាំដុះស្រូវក្នុងប្រទេសកម្ពុជា ហើយដីនេះសមស្របទៅនឹងផលិតកម្មស្រូវ។ ការគ្រប់គ្រងទឹកបានល្អគឺជាលក្ខខណ្ឌដ៏ប្រសើរសម្រាប់ការបង្កើនទិន្នផលស្រូវ។ ដីនេះមានជីជាតិមធ្យម តាមការពិសោធន៍នៅផ្ទះកញ្ចក់បង្ហាញថាដីនេះជួបបញ្ហាខ្វះជីធាតុ អាសូត ផូស្វ័រ ប៉ូតាស្យូម និងអាចខ្វះស្ពាន់ធ័រ ទៀតផង។ នៅតាមស្រែ គេសង្កេតឃើញថា វាហាក់បីដូចជាមានការឆ្លើយតបទៅនឹងការប្រើប្រាស់ជីជាតិអាសូត (N) ផូស្វ័រ (P) ប៉ូតាស្យូម (K)។



### ៤.៦ ក្រុមដី ក្បាលពោធិ

ដីក្រុមនេះមានពណ៌ប្រផេះក្រមៅ ឬត្នោតក្រមៅខ្លាំងទៅខ្មៅ ដីស្រទាប់លើជាឥដ្ឋ មានក្រហែងជ្រៅហើយធំ ស្រទាប់ក្រោមជាឥដ្ឋ។ ដីប្រភេទនេះកើតឡើងនៅលើទំនាបលិចទឹកសកម្ម។ តាមការប៉ាន់ស្មាន ដីនេះមានប្រហែល ១៣ ភាគរយ នៃផ្ទៃដីដាំដុះស្រូវទាំងមូល។ ដីក្បាលពោធិត្រូវចែកចេញជាពីរអនុក្រុម អាស្រ័យទៅតាមលក្ខណៈគីមីរបស់វាគឺ អនុក្រុមស្បូនិច និងអនុក្រុមមិនស្បូនិក។ ដីប្រភេទនេះ

Cambodian Agricultural Research and Development Institute (CARDI)

មានការងាយស្រួលក្នុងការគ្រប់គ្រង ដោយសារវាមានសក្ដានុពលភាពខ្ពស់សម្រាប់ផលិតកម្មដំណាំស្រូវ និងមានការឆ្លើយតបល្អទៅនឹងការគ្រប់គ្រង។ ដីប្រភេទនេះមានលក្ខណៈសមស្របទៅនឹងការស្រោចស្រព។ ដីស្រទាប់ក្រោមនៃអនុក្រុមស្បូនិច ជាដីអាស៊ីតមាន pH តូចជាង ៤,៥ វាអាចមានឥទ្ធិពលដល់ការលូតលាស់របស់ដំណាំ ប្រសិនបើដីនេះ ត្រូវបានគេត្រឡប់មកស្រទាប់លើដោយការភ្ជួរជ្រៅពេក។

### ៤.៧ ក្រុមដី កៀនស្វាយ



ក្រុមដីកៀនស្វាយ មានវាយនភាពជាដីឥដ្ឋ ឬល្បាយទាំងពីរស្រទាប់ ហើយមានពណ៌ត្នោត។ ដីនេះ មានការវិវត្តន៍ខ្សោយ បើយើងពិនិត្យមើលពំនុះកាត់ទទឹងរបស់វា។ ដីកៀនស្វាយ កើតឡើងនៅលើជម្រាលច្រាំងទន្លេ ឬនៅលើជម្រាលក្រោយច្រាំងទន្លេផងដែរ។

ក្រុមដីកៀនស្វាយមានផ្ទៃក្រឡាប្រមាណតិចជាង ២ ភាគរយ បើប្រៀបធៀបទៅនឹងផ្ទៃដីដាំស្រូវទាំងមូល។ ក្រុមដីនេះពុំទាន់មានអនុក្រុមនៅឡើយទេ។




ក្រុមដីកៀនស្វាយ ងាយស្រួលគ្រប់គ្រង និងមានសក្ដានុពលខ្ពស់សម្រាប់ផលិតកម្មកសិកម្ម។ ដីកៀនស្វាយ មានការឆ្លើយតបទៅនឹងការគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រ។ ដីនេះអាចខ្វះដីជាតិអាសូត និងផូស្វ័រ ហើយមានភាពឆ្លើយតបទៅនឹងការប្រើប្រាស់ជីផូស្វ័រនៅលើស្រែកសិករ តែទោះជាមានការខ្វះខាតក៏ដោយ ក៏មិនចាំបាច់ប្រើជីផូស្វ័រ ខ្ពស់ដែរ។

### ៤.៨ ក្រុមដី ទួលសំរោង

ដីនេះកើតឡើងនៅលើល្បាប់ជំនន់ចាស់ ឬល្បាប់សំណឹក ដែលមានវាយនភាពស្រទាប់លើជាឥដ្ឋ ឬល្បាយ។ ដីនេះមានក្រហែងធំជម្រៅជ្រៅជាង ៥ ស.ម ស្រទាប់ក្រោមជាឥដ្ឋ ឬល្បាយ។ ដីស្រទាប់លើមានពណ៌ប្រផេះ ឬត្នោត ប៉ុន្តែមិនមែនប្រផេះក្រមៅ ឬខ្មៅទេ។

ក្រុមដីទួលសំរោង មានប្រហែល ១០ ភាគរយ នៃផ្ទៃដីដាំស្រូវ។ ដីនេះចែកជាពីរអនុក្រុម អាស្រ័យទៅតាមពណ៌ និងដីជាតិរបស់ដីគឺ អនុក្រុមពណ៌ត្នោត និងអនុក្រុមពណ៌ប្រផេះ។



ដីនេះសមស្របចំពោះផលិតកម្មស្រូវ ពោលគឺមានសក្ដានុពលពីបង្គួរទៅខ្ពស់ហើយមានការឆ្លើយតបល្អ ចំពោះការគ្រប់គ្រងកែច្នៃ ពិសេសចំពោះការស្រោចស្រព។

តាមការសង្កេតកន្លងមក ដីនេះមានការឆ្លើយតបល្អចំពោះតែការប្រើប្រាស់ N និង P ប៉ុណ្ណោះ។

### ៤.៩ ក្រុមដី គោកត្រប់

ដីក្រុមគោកត្រប់កើតឡើងនៅលើល្បាប់ជំនន់ចាស់ ដែលមានវាយនភាពដីស្រទាប់លើជាល្បាយ ឬឥដ្ឋ ពណ៌ប្រផេះចាស់ ឬត្នោតក្រមៅទៅខ្មៅ ដីស្រទាប់ក្រោមជាល្បាយ ឬឥដ្ឋ ពណ៌ប្រផេះ ឬត្នោតខ្ចី។

Cambodian Agricultural Research and Development Institute (CARDI)

ដីនេះមាននៅភាគខាងត្បូងនៃប្រទេសកម្ពុជា ពិសេសនៅក្នុងខេត្ត ព្រៃវែង និងស្វាយរៀង ហើយមួយភាគតូចទៀតនៅខេត្តកណ្តាល និងតាកែវ។ ក្រុមដីគោកត្រប់ មានប្រហែល ៥ ភាគរយ នៃផ្ទៃដីដាំដុះស្រូវនៅកម្ពុជា។ ដីនេះត្រូវបានចែកចេញជាពីរអនុក្រុមដាច់ពីគ្នាគឺ អនុក្រុមមានដីជាតិ និងអនុក្រុមគ្មានដីជាតិ។

## ៤.១០ ក្រុមដី កំពង់សៀម




ក្រុមដីកំពង់សៀម កើតឡើងនៅលើផ្នែកនៃសណ្ឋានដីប្រែប្រួលខ្ពស់ទាបមិនរាបស្មើ ដែលមានវាយនភាពស្រទាប់លើជាដីឥដ្ឋមានពណ៌ខ្មៅ ឬប្រផេះក្រម៉ៅ មានក្រហែងធំជ្រៅ ដីស្រទាប់ក្រោមជាដីឥដ្ឋពណ៌ប្រផេះ។ ក្រុមដីនេះជាដីក្មេងមានប្រហែល ២ ភាគរយ នៃផ្ទៃដីដាំស្រូវទាំងអស់នៅប្រទេសកម្ពុជា។ ដីនេះត្រូវបានចែកចេញជាពីរអនុក្រុមដោយឡែកទៅលើវត្តមាន និងអវត្តមាននៃក្រួស។

ដីនេះសមស្របសម្រាប់ផលិតកម្មស្រូវ ឯទិន្នផលឆ្លើយតបល្អទៅនឹងការគ្រប់គ្រងបែបទំនើប។ ការពិសោធន៍នៅផ្ទះកញ្ចក់បានបង្ហាញថា ក្រុមដីកំពង់សៀម មានកង្វះសារធាតុអាសូត និងផូស្វ័រ។ ជម្រៅរបស់ឫសមិនមានការកំណត់ទេ សមត្ថភាពស្តុកទឹកទុករបស់ដីស្រទាប់លើល្អ ប៉ុន្តែក្នុងកំឡុងពេលមានភ្លៀងតិច ដីនេះអាចហួតហែងដោយសារតែវាអាចស្តុបទឹកបានតិចតួច។

Cambodian Agricultural Research and Development Institute (CARDI)

លក្ខណៈសម្បត្តិសំខាន់ៗរបស់ក្រុមដីទាំង ១១ សម្រាប់ជំនួយក្នុងការធ្វើចំណាត់ថ្នាក់ដីដាំស្រូវនៅកម្ពុជា

| ល.រ | ក្រុមដី | សណ្ឋានដី | វាយនភាព | | ក្រហែង | ពណ៌ | លក្ខណៈពិសេស |
|---|---|---|---|---|---|---|---|
| | | | ស្រទាប់លើ | ស្រទាប់ក្រោម | | | |
| ០ | ព្រៃខ្មែរ | តំបន់វាលរាប, តំបន់ខ្ពស់ទាបមិនរាបស្មើ | ខ្សាច់ | ខ្សាច់ | គ្មាន | ប្រផេះទៅត្នោតភ្លឺ | ស្រទាប់ខ្សាច់ជ្រៅ |
| ១ | ប្រទះឡាង | តំបន់វាលរាប | ខ្សាច់ | ល្បាយ, ឥដ្ឋ | គ្មាន | ប្រផេះទៅត្នោតភ្លឺ | ដីហាប់ក្រោយពេលភ្ជួររាស់ |
| ២ | ឡាបានសៀក | តំបន់ភ្នំ | ឥដ្ឋ | ឥដ្ឋ | មាន | ក្រហមទៅក្រហមក្រមៅ | ដីក្រហមចម្ការកៅស៊ូ |
| ៣ | អូររាំង | តំបន់វាលរាប | ល្បាយ, ឥដ្ឋ | ខ្សាច់ | រាក់ | ប្រផេះទៅប្រផេះភ្លឺ | ស្រទាប់លើល្បាយ ឬឥដ្ឋ ស្រទាប់ក្រោមខ្សាច់ |
| ៤ | ក្រគរ | តំបន់ទំនាបជំនន់ | ល្បាយ, ឥដ្ឋ | ឥដ្ឋ | ពីរាក់ទៅជ្រៅ | ប្រផេះ, ត្នោត | ភាគច្រើនមាននៅជុំវិញបឹងទន្លេសាប |
| ៥ | បាកាន | តំបន់វាលរាប | ល្បាយ, ឥដ្ឋ | ល្បាយ, ឥដ្ឋ | គ្មាន ឬ រាក់ | ប្រផេះភ្លឺទៅត្នោត | |
| ៦ | ក្បាលពោធិ | តំបន់ទំនាបជំនន់ | ឥដ្ឋ | ឥដ្ឋ | ជ្រៅ | ប្រផេះក្រមៅទៅខ្មៅ | |
| ៧ | កៀនស្វាយ | តំបន់ច្រាំង ឬ ជម្រាលច្រាំង | ល្បាយ, ឥដ្ឋ | ល្បាយ, ឥដ្ឋ | មាន | ប្រផេះ, ត្នោត | ស្រទាប់ដីលើ និងក្រោមមិនសូវខុសគ្នា |
| ៨ | ទួលសំរោង | តំបន់វាលរាប, តំបន់ខ្ពស់ទាបមិនរាបស្មើ | ល្បាយ, ឥដ្ឋ | ល្បាយ, ឥដ្ឋ | ជ្រៅ | ប្រផេះ, ត្នោត | ដីបាត់ដំបង |
| ៩ | គោកត្រប់ | តំបន់វាលរាប, តំបន់វាលរាប | ល្បាយ, ឥដ្ឋ | ល្បាយ, ឥដ្ឋ | មាន | ប្រផេះក្រមៅទៅខ្មៅ | |
| ១០ | កំពង់សៀម | តំបន់ខ្ពស់ទាបមិនរាបស្មើ | ឥដ្ឋ | ឥដ្ឋ | ជ្រៅ | ខ្មៅ | ច្រើនមានក្រួស ឬ ថ្មបាសាល |



Cambodian Agricultural Research and Development Institute (CARDI)



**សម្គាល់៖** សម្រាប់ព័ត៌មានលម្អិតមួយចំនួនទៀត ទាក់ទងទៅនឹងក្រុមដីទាំង ១១ ក្រុម សូមអានសៀវភៅ "ដីប្រើប្រាស់សម្រាប់ផលិតកម្មស្រូវនៅប្រទេសកម្ពុជា" ដែលបោះពុម្ពនៅឆ្នាំ១៩៩៧ ដោយអង្គការកម្មវិធីកម្ពុជា-អ៊ីរី-អូស្ត្រាលី (CIAP)។

## ៥. ការផ្សព្វផ្សាយបច្ចេកទេសធ្វើចំណាត់ថ្នាក់ដី

ការបង្កើតឡើងនូវយុទ្ធសាស្ត្រសមស្របនៅក្នុងការផ្ទេរបច្ចេកវិទ្យានេះ ជាកត្តាកំណត់យ៉ាងសំខាន់ដល់ការពង្រីកនូវចំណេះដឹងរបស់កសិករលើលក្ខណៈដី ប្រភេទដី និងវិធីសាស្ត្រធ្វើចំណាត់ថ្នាក់ដី ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការប្រើប្រាស់ដីរបស់កសិករ។ យុទ្ធសាស្ត្រខាងក្រោមនេះគ្រាន់តែជាជម្រើសមួយនៅក្នុងការផ្ទេរបច្ចេកវិទ្យានេះដល់កសិករ ហើយវាក៏ផ្តល់នូវចំនេះដឹងជាមូលដ្ឋានសម្រាប់លោកអ្នក ជាពិសេសភ្នាក់ងារផ្សព្វផ្សាយយកទៅអនុវត្តបត់បែនទៅតាមស្ថានភាពជាក់ស្តែងរបស់កសិករ។

### ៥.១ វិធីសាស្ត្រក្នុងការផ្ទេរបច្ចេកវិទ្យា

ការផ្ទេរបច្ចេកវិទ្យានេះទៅដល់កសិករ គឺធ្វើឡើងតាមរយៈការបណ្តុះបណ្តាល ដែលទាក់ទងទៅនឹងការជ្រើសរើសពេលវេលាសមស្រប ការជ្រើសរើសកសិករដែលត្រូវចូលរួមកំណត់ក្រុមពិភាក្សា ដើម្បីធ្វើឲ្យការកំណត់ចំណាត់ថ្នាក់ដីនេះទទួលបាននូវប្រសិទ្ធភាពខ្ពស់ ដូច្នេះភ្នាក់ងារផ្សព្វផ្សាយ ឬអ្នកពាក់ព័ន្ធផ្សេងៗ គួរតែអនុវត្តតាមដំណាក់កាលជាបន្តបន្ទាប់ដូចខាងក្រោមនេះ៖

#### *ក. ពេលវេលាសមស្របក្នុងពេលធ្វើចំណាត់ថ្នាក់ដី*

ជាទូទៅចំណាត់ថ្នាក់ដីធ្វើនៅក្នុងអំឡុងខែមេសា ឧសភា និងមិថុនា ក្រោយពេលភ្លៀងធ្លាក់ពីរទៅបីដង។ ក្នុងអំឡុងពេលនោះ ដីមានសភាពសើមល្មម (ដីធូ) ងាយកាប់ ឬជីកដើម្បីមើលស្រទាប់ដី។ ផ្ទុយទៅវិញ ប្រភេទដីខ្សាច់អាចធ្វើចំណាត់ថ្នាក់បានគ្រប់ពេលវេលា។

#### *ខ. ការជ្រើសរើសទីតាំង*

ចំណាត់ថ្នាក់ដីគឺអាចធ្វើឡើងនៅលើដីកសិកម្មក្នុងភូមិ ឃុំ ស្រុក ឬខេត្ត ជាទីកន្លែងដែលកសិកររស់នៅនិងធ្វើស្រែចម្ការ។ រយៈពេលនៃការជ្រើសរើសទីតាំងនេះ គឺកំណត់មួយថ្ងៃ តែអាចតិច ឬច្រើនជាងមួយថ្ងៃអាស្រ័យទៅតាមតំបន់ (ឆ្ងាយ ឬជិត) និងតម្រូវការប្រភេទដីច្រើនកន្លែង។

#### *គ. ការជ្រើសរើសកសិករ*

ជ្រើសរើសកសិករគំរូ (ធ្វើស្រែចម្ការ និងយកចិត្តទុកដាក់ចំពោះការងារកសិកម្ម) ចំនួន ១៥ នាក់ ដែលមានចំណេះដឹងមធ្យម (អាចអាន និងសរសេរបាន) និងមានចំណាប់អារម្មណ៍លើដីកសិកម្ម និងមានមន្ត្រីផ្សព្វផ្សាយចំនួន ៥

Cambodian Agricultural Research and Development Institute (CARDI)

នាក់ ដើម្បីធ្វើការសម្របសម្រួល។

***ឃ. ការបណ្តុះបណ្តាល***

**ការបង្ហាត់បង្រៀនដល់កសិករពីការធ្វើចំណាត់ថ្នាក់ដីនេះ គឺចែកជាពីរដំណាក់កាលៈ**

- ណែនាំបច្ចេកទេសចំណាត់ថ្នាក់ដីនេះដល់កសិករ ដើម្បីឲ្យគាត់យល់ដឹងពីអត្ថប្រយោជន៍នៃបច្ចេកទេសនេះ។ ប្រធានបទសំខាន់ៗមានៈ មេរៀនទ្រឹស្តី បញ្ញត្តិ វិធីសាស្រ្តចំណាត់ថ្នាក់ដី ត្រូវការពេលវេលាកន្លះថ្ងៃ។
- ចុះអនុវត្តន៍ជាក់ស្តែងៈ បែងចែកក្រុមកសិករជា ៣ ក្រុម ដែលមានអ្នកសម្របសម្រួល ១ នាក់ ក្នុងមួយក្រុម។ ក្រុមនីមួយៗត្រូវចុះអនុវត្តន៍ផ្ទាល់ ដោយធ្វើការពិភាក្សាក្នុងក្រុម និងឡើងបង្ហាញលទ្ធផល។ រយៈពេលអនុវត្តន៍ជាក់ស្តែងនេះ គឺបានកំណត់កន្លះថ្ងៃ តែអាចច្រើនជាងនេះគឺអាស្រ័យទៅតាមតម្រូវការចង់ដឹងកាន់តែច្បាស់ពីបច្ចេកទេសនេះ និងធនធាន។
- សម្ភារៈសម្រាប់ជំនួយដល់ការធ្វើចំណាត់ថ្នាក់ដីៈ សម្ភារៈធ្វើចំណាត់ថ្នាក់ដីសាមញ្ញមួយចំនួន គឺអាចរកបាននៅក្នុងស្រុក មានដូចជា ចបកាប់ ចបជីក បង្គី សៀវភៅចំណាត់ថ្នាក់ដី និងឯកសារបទដ្ឋានអនុវត្តន៍បច្ចេកទេសចំណាត់ថ្នាក់ដីសម្រាប់ដំណាំស្រូវ។

| ល.រ | មុខចំណាយ | ឯកតា | បរិមាណ |
|---|---|---|---|
| ១ | ការចំណាយសម្រាប់ភ្នាក់ងារផ្សព្វផ្សាយ | នាក់/ថ្ងៃ | ៤ x ២ |
| ២ | សោហ៊ុយធ្វើដំណើររបស់កសិករ | នាក់/ថ្ងៃ | ១៥ x ១ |
| ៣ | អាហារថ្ងៃត្រង់ និងអាហារសម្រន់ | នាក់/ថ្ងៃ | ១៥ x ១ |
| ៤ | ឯកសារផ្សព្វផ្សាយ | សម្រាប់ | ១៥ |
| ៥ | សម្ភារៈលើកទឹកចិត្តកសិករ | សម្រាប់ | ១៥ |
| ៦ | សម្ភារៈសម្របសម្រួល | សម្រាប់ | ១ |

៤.២ ការចំណាយលើការផ្សព្វផ្សាយ

**បណ្ណាល័យសាស្រ្ត**

ភីធើរវ៉ាយ តូម៉ាស់អូបឺត័រ និង ភាវ សុវុទ្ធី (១៩៩៧)។ ដីប្រើប្រាស់សម្រាប់ផលិតកម្មដំណាំស្រូវនៅកម្ពុជា (បោះពុម្ពលើកទី ៤)។ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា។ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

White, P.F., Oberthur, T. and Pheav, S. 1997. The soils used for rice production in Cambodia, A manual for their recognition and management. Manila, Philippines, International Rice Research Institute, 71 p (Chapter 3: 21-29).

Cambodian Agricultural Research and Development Institute (CARDI)

# របៀបប្រើប្រាស់ជី N P K សម្រាប់ដំណាំស្រូវ

**សារ**ធាតុចិញ្ចឹមខនិជ N P និង K ជាសារធាតុដ៏សំខាន់ក្នុងចំណោមសារធាតុចិញ្ចឹមផ្សេងៗទៀត ដែលរុក្ខជាតិត្រូវការដើម្បីទ្រទ្រង់ការលូតលាស់ និងផ្តល់ផ្លែផ្ការបស់វា។ ដីភាគច្រើននៅប្រទេសកម្ពុជា ជាពិសេសដីសម្រាប់ដំណាំស្រូវ ពុំអាចផ្គត់ផ្គង់សារធាតុចិញ្ចឹមខនិជទាំងនេះឲ្យបានគ្រប់គ្រាន់តាមតម្រូវការរបស់ដំណាំឡើយ។ ដូច្នេះដើម្បីធានាបាននូវការលូតលាស់ជាប្រក្រតីរបស់ដំណាំ គេចាំបាច់ត្រូវតែបាចជីបន្ថែមឲ្យបានត្រឹមត្រូវទៅតាមតម្រូវការរបស់ដំណាំ និងអនុវត្តឲ្យបានខ្ជាប់ខ្ជួនតាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងនូវការខាតបង់ថវិកា ពេលវេលា និងផលប៉ះពាល់ដល់បរិស្ថាន។ ម្យ៉ាងទៀត បរិមាណជីដែលត្រូវប្រើ ក៏អាស្រ័យផងដែរទៅនឹងប្រភេទដី ពូជដំណាំ របបទឹក និងកត្តាបរិស្ថានផ្សេងៗទៀត។

**ខាង**ក្រោមនេះគឺជាអនុសាសន៍ នៃការប្រើប្រាស់ជីគីមីលើដំណាំស្រូវ ដែលដាំដុះលើ **"ក្រុមដីបាកាន"** នៃតំបន់ទំនាបអាស្រ័យទឹកភ្លៀងនៅប្រទេសកម្ពុជា។



**ក្រុមដីបាកាន** កកើតឡើងលើតំបន់ទំនាបល្បាប់ចាស់ ដែលមានកំណើតមកពីសំណឹកនៃសារធាតុផ្សេងៗពីតំបន់ភ្នំ និងដីល្បាប់ពីទន្លេ។ ពេលមានទឹកជំនន់ធំ តំបន់នៃដីនេះតែងតែទទួលដីល្បាប់ពីជំនន់ទន្លេ ឬបឹងដែរ។ គេប្រទះឃើញក្រុមដីនេះគ្រប់ទីកន្លែង នៃតំបន់ធ្វើស្រែក្នុងប្រទេសកម្ពុជា ហើយតាមការប៉ាន់ស្មានក្រុមដីនេះមានប្រមាណ ១០-១៥ ភាគរយ នៃផ្ទៃដីដាំស្រូវសរុប។ នៅតំបន់ដែលមិនទាន់មានការរុករានធ្វើស្រែ គេតែងតែសង្កេតឃើញមានព្រៃត្រពិកក្រាស់ល្មមដុះលូតលាស់លើប្រភេទដីនេះ។

### កម្រិតប្រើប្រាស់ជីគីមី ក្នុងលក្ខខណ្ឌទូទៅសម្រាប់ក្រុមដីបាកាន មានដូចខាងក្រោម៖

**១-កម្រិតណែនាំទី ១** (ប្រើសម្រាប់ពូជទំនើប)៖ ៧៥:៣០:០-៣០ (N, $P_2O_5$, $K_2O$, គ.ក្រ /ហ.ត) ដែលត្រូវបាចដូចតទៅ៖

**+ជីទ្រាប់បាត**

- អ៊ុយរ៉េ (Urea) ៖ ១៣៨ គ.ក្រ/ហ.ត
- ដេ អា ប៉េ (DAP) ៖ ៦៥ គ.ក្រ/ហ.ត
- ប៉ូតាស្យូ (KCL) ៖ ០-៥០ គ.ក្រ/ហ.ត

**+ជីបំប៉នលើកទី ១** (បាច ៣០ ថ្ងៃក្រោយស្ទូង)៖ បាចជីអ៊ុយរ៉េចំនួន ៦៥ គ.ក្រ/ហ.ត

**+ជីបំប៉នលើកទី ២** (បាចពេលកំណាត់កំណើតកួរ)៖ បាចជីអ៊ុយរ៉េចំនួន ៤៩ គ.ក្រ/ហ.ត

**២-កម្រិតណែនាំទី ២** (ប្រើសម្រាប់ពូជប្រពៃណី)៖ ៦០:២០:០-២០ (N, $P_2O_5$, $K_2O$, គ.ក្រ /ហ.ត) ដែលត្រូវបាចដូចតទៅ៖

**+ជីទ្រាប់បាត**



Cambodian Agricultural Research and Development Institute (CARDI)

- អ៊ុយរ៉េ (Urea) ៖ ១១៣ គ.ក្រ/ហ.ត
- ដេ អា ប៉េ (DAP) ៖ ៤៣ គ.ក្រ/ហ.ត
- ប៉ូតាស្យូ (KCL) ៖ ០-៣៣ គ.ក្រ/ហ.ត

+**ជីបំប៉នលើកទី ១** (បាច ៣០ ថ្ងៃក្រោយស្ទូង)៖ បាចជីអ៊ុយរ៉េចំនួន ៥២ គ.ក្រ/ហ.ត

+**ជីបំប៉នលើកទី ២** (បាចពេលកំណាត់កំណើតកួរ)៖ បាចជីអ៊ុយរ៉េចំនួន ៣៩ គ.ក្រ/ហ.ត

**ចំពោះ**ដីប្រភេទនេះ ការប្រើប្រាស់ជីអាសូត (N) និងផូស្វ័រ (P) តែងតែទទួលបានលទ្ធផលល្អ ប៉ុន្តែចម្លើយតបទៅលើជីប៉ូតាស្យូម មានលក្ខណៈទាប និងមានការប្រែប្រួលទៀតផង។ ចម្លើយតបទៅនឹងជីប៉ូតាស្យូម នៅមានកម្រិតក្នុងលក្ខខណ្ឌដាំដុះមិនគាប់ប្រសើរ ហើយបើនៅលើដីដែលមានជីជាតិល្អនៃក្រុមដីបាកាន ការដាក់ជីប៉ូតាស្យូមពុំស្តែងចេញនូវប្រសិទ្ធភាពរបស់វាទេ។ ក្នុងករណីនេះពុំគួរប្រើជីប៉ូតាស្យូមទេ ប៉ុន្តែបើក្នុងលក្ខខណ្ឌធម្មតាគេអាចប្រើជីប៉ូតាស្យូមរហូតដល់មួយបាវក្នុងមួយហិកតា។ ក្នុងលក្ខខណ្ឌនៃការដាំដុះដែលមានលក្ខណៈប្រពលវប្បកម្ម រយៈពេលប្រហែល ៥ ឆ្នាំ ការប្រើប្រាស់ជី K អាចមានប្រសិទ្ធភាព។ ប្រសិនបើតម្លៃផលស្រូវខ្ពស់ ហើយស្រែមានទឹកគ្រប់គ្រាន់សម្រាប់ដាំដុះនោះគេគួរប្រើកម្រិតជី N និង P ឲ្យបានខ្ពស់នៅលើដីប្រភេទនេះ (១២០:៦០:៣០)។ ពូជទំនើបតែងតែផ្តល់ទិន្នផលខ្ពស់ជាងពូជប្រពៃណីនៅលើដីប្រភេទនេះ ទោះបីជាដាក់ ឬមិនដាក់ជីក៏ដោយ។ កម្រិតជីណែនាំខ្ពស់គឺប្រើសម្រាប់តែការដាំដុះពូជស្រូវទំនើបប៉ុណ្ណោះ។

## កម្រិតជីណែនាំសម្រាប់ផលិតកម្មដំណាំស្រូវ

ក្រុមដីព្រៃខ្មែរ (Prey Khmer)

២៨:១០:៤០ *ពូជស្រូវទំនើប ឬពូជស្រូវប្រពៃណី* ត្រូវនឹងជីអ៊ុយរ៉េមួយបាវ (៥០ គ.ក) DAP កន្លះបាវ និងជីប៉ូតាស្យូម ១$^{១}/_{៣}$ បាវ (ឬ ៦៧ គ.ក)។

២០:០៨:០០ ***ពូជស្រូវទំនើប ឬពូជស្រូវប្រពៃណី*** ត្រូវនឹងជីអ៊ុយរ៉េ $^{៣}/_{៤}$ បាវ (ឬ៣៨ គ.ក) DAP $^{១}/_{៣}$ បាវ (ឬ ១៧ គ.ក)។

**ដី**ប្រភេទនេះពុំសូវឆ្លើយតបខ្លាំងទៅនឹងការប្រើប្រាស់ជីទេ ហើយប្រសិទ្ធិភាពនៃជីអាសូតធ្លាក់ចុះ កាលណាគេពុំប្រើជីប៉ូតាស្យូម។ ប្រសិនមានទឹកគ្រប់គ្រាន់ ហើយតម្លៃស្រូវនៅលើទីផ្សារបានថ្លៃ នោះគេអាចប្រើជីក្នុងកម្រិត ៤០:១០:៥០ ឬ ២៧:១១:០០។ បើលក្ខណៈផ្ទុយពីនេះគួរកុំប្រើប្រាស់ជីប្រសើរជាង។ កម្រិតណែនាំឲ្យប្រើប្រាស់ខាងលើនេះ គឺសមស្របសម្រាប់ពូជទំនើប ឬពូជប្រពៃណី ព្រោះវាអាចផ្តល់ទិន្នផលបានប្រហាក់ប្រហែលគ្នា។

ក្រុមដីប្រទះឡាង (Prateah lang)

៥០:២៣:៣០ ***ពូជស្រូវទំនើប ឬពូជស្រូវប្រពៃណី*** ត្រូវនឹងជីអ៊ុយរ៉េ ១$^{៣}/_{៤}$ បាវ (៨៨ គ.ក) DAP មួយបាវ និងជីប៉ូតាស្យូម មួយបាវ។

៣៣:២៣:០០ ***ពូជស្រូវទំនើប ឬពូជស្រូវប្រពៃណី*** ត្រូវនឹងជីអ៊ុយរ៉េ មួយបាវ និង DAP មួយបាវ។

**ប្រសិទ្ធិភាព**នៃជីអាសូតធ្លាក់ចុះ កាលណាគេពុំប្រើជីប៉ូតាស្យូម។ កាលណាមានទឹកគ្រប់គ្រាន់ផ្សំនឹងការប្រើប្រាស់ជីប៉ូតាស្យូម ហើយផលស្រូវមានតម្លៃខ្ពស់នោះគេអាចដាក់ជីអាសូត និងផូស្វ័ររហូតដល់កម្រិត ១០០:៤០:៤០ បាន។ ប៉ុន្តែបើពុំដាក់ជីប៉ូតាស្យូមទេ ហើយស្រែពុំមានទឹកគ្រប់គ្រាន់នោះ គួរប្រើជីអាសូត និងផូស្វ័រ ក្នុងកម្រិត ៣៣:២៣:០០ ឬទាបជាងនេះ។ បើប្រើជីក្នុងកម្រិតទាប ឬមធ្យមនោះ ពូជទំនើបនឹងផ្តល់ទិន្នផលប្រហាក់ប្រហែល ឬទាបជាងពូជប្រពៃណី។ តែបើប្រើជីក្នុងកម្រិតខ្ពស់នោះ វានឹងផ្តល់ទិន្នផលខ្ពស់ជាងពូជប្រពៃណី។ គួរចាំថាបើប្រើពូជទំនើបគួរដាក់ជីឲ្យបានច្រើន។

Cambodian Agricultural Research and Development Institute (CARDI)

ក្រុមដីបាកាន ឬអូរួង (Bakan or Orung)

៧៥:៣០:៣០ ***ពូជស្រូវទំនើប*** ត្រូវនឹងជីអ៊ុយរ៉េ ២ ២/៣ បាវ (ឬ ១៣៤ គ.ក) DAP ១ ១/៣ បាវ (ឬ ៦៧ គ.ក) និងជីប៉ូតាស្យូម មួយបាវ។

៧៥:៣០:០០ ***ពូជស្រូវទំនើប*** ត្រូវនឹងជីអ៊ុយរ៉េ ២ ២/៣ បាវ (ឬ ១៣៤ គ.ក) DAP ១ ១/៣ បាវ (ឬ ៦៧ គ.ក)។

៦០:១៧:២០ ***ពូជស្រូវប្រពៃណី*** ត្រូវនឹងជីអ៊ុយរ៉េ ២ ១/៣ បាវ (ឬ ១១៧ គ.ក) DAP ៣/៤ បាវ (ឬ ៣៨ គ.ក) និងជីប៉ូតាស្យូម ២/៣ បាវ (ឬ ៣៤ គ.ក)។

៦០:១៧:០០ ***ពូជស្រូវប្រពៃណី*** ត្រូវនឹងជីអ៊ុយរ៉េ ២ ១/៣ បាវ (ឬ ១១៧ គ.ក) DAP ៣/៤ បាវ (ឬ ៣៨ គ.ក)។

**ចំពោះ**ក្រុមដីប្រភេទនេះ ការប្រើប្រាស់ជីអាសូត និងផូស្វ័រ តែងតែទទួលបានទិន្នផលល្អ ប៉ុន្តែចម្លើយតបទៅលើជីប៉ូតាស្យូម មានលក្ខណៈទាប និងមានការប្រែប្រួលទៀតផង។ ចម្លើយតបទៅនឹងជីប៉ូតាស្យូម ត្រូវបានក្រិតត្បិតក្នុងលក្ខខណ្ឌដាំដុះមិនគាប់ប្រសើរ ហើយបើនៅលើដីដែលមានជីជាតិល្អនៃក្រុមដីបាកាន ការដាក់ប៉ូតាស្យូម ពុំស្តែងចេញនូវប្រសិទ្ធិភាពរបស់វាទេ។ ក្នុងករណីនេះពុំគួរប្រើជីប៉ូតាស្យូមទេ ប៉ុន្តែបើលក្ខខណ្ឌនៃការដាំដុះមានលក្ខណៈប្រពលវប្បកម្មរយៈពេលប្រហែល ៥ ឆ្នាំ ការប្រើប្រាស់ជីប៉ូតាស្យូម អាចមានប្រសិទ្ធិភាព។ ប្រសិនបើតម្លៃផលស្រូវខ្ពស់ ហើយស្រែមានទឹកគ្រប់គ្រាន់សម្រាប់ដាំដុះនោះគួរប្រើកម្រិតជីអាសូត និងផូស្វ័រ ឲ្យបានខ្ពស់នៅលើដីប្រភេទនេះ (១២០:៦០:៣០) ។ ពូជទំនើបតែងតែផ្តល់ទិន្នផលខ្ពស់ជាងពូជប្រពៃណី នៅលើដីប្រភេទនេះ ទោះបីជាដាក់ ឬមិនដាក់ជីក៏ដោយ។ កម្រិតជីណែនាំខ្ពស់គឺ ប្រើសម្រាប់តែការដាំដុះពូជស្រូវទំនើបប៉ុណ្ណោះ។

ក្រុមដីទួលសំរោង (Toul Samroung)

៩៨:៣៥:០០ ***ពូជស្រូវទំនើប*** ត្រូវនឹងជីអ៊ុយរ៉េ ៣ ២/៣ បាវ (ឬ ១៩៤ គ.ក) និង DAP ១ ១/២ បាវ (ឬ ៧៥ គ.ក)។

៦១:២៤:០០ ***ពូជស្រូវប្រពៃណី*** ត្រូវនឹងជីអ៊ុយរ៉េ ២ ១/៣ បាវ (ឬ ១១៣ គ.ក) និង DAP មួយបាវ។

**ការ**ប្រើប្រាស់ជីអាសូត និងជីផូស្វ័រ នៅលើដីប្រភេទនេះ ផ្តល់នូវចម្លើយតបយ៉ាងខ្លាំងសមស្របទៅនឹងតម្រូវការរបស់ដំណាំស្រូវ។ ជាទូទៅការប្រើប្រាស់ប៉ូតាស្យូម ពុំមានប្រសិទ្ធិភាពទេ លើកលែងតែតំបន់ខ្លះ (ដីមានពណ៌ស្រាលជាង) ដែលដីមានលក្ខណៈហូរច្រោះខ្លាំងជាងធម្មតា។ ចំពោះដីបែបនេះ (មានការហូរច្រោះខ្លាំង) គួរប្រើប៉ូតាស្យូម មួយបាវក្នុងមួយហិកតា ជាមួយនឹងកម្រិតជីអាសូត និងផូស្វ័រ ឲ្យបានទិន្នផលខ្ពស់ជាងនេះ ដើម្បីបានចំណេញ (ខ្ពស់ជាង ១២០:៤០:០០ ឬច្រើនជាង ៤ បាវ ជីអ៊ុយរ៉េ និង ១ ១/៣ បាវជី DAP)។ ពី ៤ ទៅ ៥ ឆ្នាំ ក្រោយពីការប្រើប្រាស់កម្រិតជីខ្ពស់បែបនេះ តម្រូវការនៃជីប៉ូតាស្យូម នឹងកើនឡើងយ៉ាងច្បាស់។ ទោះជាដាក់ ឬមិនដាក់ជីក្តីក៏ពូជទំនើបផ្តល់ផលខ្ពស់ជាងពូជប្រពៃណីដែរ។ កម្រិតណែនាំសម្រាប់ពូជប្រពៃណីដែរ។ កម្រិតណែនាំខ្ពស់ៗ គឺប្រើសម្រាប់តែពូជទំនើបតែប៉ុណ្ណោះ។

ក្រុមដីកំពង់សៀម (Kampong Siem)

៥០:០០:០០ ***ពូជស្រូវទំនើប ឬពូជស្រូវប្រពៃណី*** ត្រូវនឹងជីអ៊ុយរ៉េ ២ បាវកន្លះ ដោយមិនចាំបាច់ប្រើជី P និង K។

**ការ**ប្រើជីអាសូត (N) មានប្រសិទ្ធិភាពល្អ រីឯប្រសិទ្ធិភាពនៃការប្រើជីផូស្វ័រ (P) មានការប្រែប្រួល ហើយគេសង្កេតឃើញមានការឆ្លើយតបតិចតួចទៅនឹងការប្រើប្រាស់ជីផូស្វ័រ ក្នុងរដូវវស្សា តែវាពុំមានផលចំណេញទេ។ ចំណែកឯជីប៉ូតាស្យូម (K) ពុំមានប្រសិទ្ធិភាពទេ។ ប្រសិនបើប្រើពូជទំនើបនៅរដូវប្រាំង ដែលមានលក្ខខណ្ឌល្អនោះ ការដាក់ជី អាសូត (N) និងផូស្វ័រ (P) ឲ្យបានខ្ពស់ជាងនេះអាចមានផលចំណេញ (គឺ ៩៨:១៨:០០ ត្រូវនឹងជីអ៊ុយរ៉េ ៤ បាវ និងជី DAP ៣/៤ បាវ)។

Cambodian Agricultural Research and Development Institute (CARDI)

ក្រុមដីគោកត្រប់ខ្សត់ជីវជាតិ (Koktrap, Infertilenphase)

៧៣:៣៥:៣០ ***ពូជស្រូវទំនើប*** ត្រូវនឹងជីអ៊ុយរ៉េ ២$^{១}/_{២}$ បាវ DAP ១$^{១}/_{២}$ បាវ និងជីប៉ូតាស្យូម មួយបាវ។

៦៥:៣០:០០ ***ពូជស្រូវទំនើប*** ត្រូវនឹងជីអ៊ុយរ៉េ ១$^{១}/_{៣}$ បាវ (ឬ ៦៧ គ.ក)។

៥៨:៣១:៣០ ***ពូជស្រូវប្រពៃណី*** ត្រូវនឹងជីអ៊ុយរ៉េ ២ បាវ DAP ១$^{១}/_{៣}$ បាវ និងជីប៉ូតាស្យូម មួយបាវ។

៤៩:២៣:០០ ***ពូជស្រូវប្រពៃណី*** ត្រូវនឹងជីអ៊ុយរ៉េ ១$^{៣}/_{៤}$ បាវ (ឬ ៨៨ គ.ក) និង DAP មួយបាវ។

បើពុំដាក់ជីអាសូត និងជីផូស្វ័រ ទេនោះ ដំណាំស្រូវពុំលូតលាស់ល្អទេ។ កាលណាគេដាក់ជីអាសូត និងជីផូស្វ័រ ជាមួយគ្នានោះនឹងមានប្រសិទ្ធិភាពយ៉ាងសមស្រប។ ការដាក់ជីអាសូត តែមួយមុខទំនងជាមិនបង្កើនទិន្នផលទេ ផ្ទុយទៅវិញអាចធ្វើឲ្យទិន្នផលថយចុះថែមទៀតផង។ ពូជប្រពៃណីផ្តល់ផលបានខ្ពស់ជាងពូជទំនើប កាលណាគេពុំបានប្រើជី។ តែពូជទំនើបអាចផ្តល់ផលបានច្រើនជាងពូជប្រពៃណី កាលណាគេប្រើជីកម្រិតណែនាំខាងលើ។ បើស្រែមានទឹកគ្រប់គ្រាន់ និងស្រូវមានតម្លៃខ្ពស់នោះ គេអាចប្រើកម្រិតជីខ្ពស់ជាងកម្រិតជីណែនាំនេះជាមួយពូជទំនើបខ្ពស់ជាង ១២២:៤៦:៤០ ត្រូវនឹងជីអ៊ុយរ៉េ ៤ បាវកន្លះ ជី DAP ២ បាវ និងជីប៉ូតាស្យូម ១$^{១}/_{៣}$ បាវ។

ក្រុមដីក្បាលពោធិ (Kbal Po)

៨០:០០:០០ ***ពូជស្រូវទំនើប*** ត្រូវនឹងជីអ៊ុយរ៉េ ២ បាវកន្លះ។

ដីក្រុមនេះមានជីជាតិល្អ ហើយមានការឆ្លើយតបទៅនឹងការប្រើជីអាសូត លើដំណាំស្រូវប្រាំង ឬស្រូវប្រដេញទឹក។ ជាទូទៅ ប្រភេទដីនេះពុំមានការឆ្លើយតបទៅនឹងការប្រើជីផូស្វ័រទេ។ បើមានទឹកគ្រប់គ្រាន់ និងស្រូវមានតម្លៃខ្ពស់ គួរប្រើជីអាសូត ក្នុងកម្រិតខ្ពស់ជាងនេះ (ខ្ពស់ជាង ១២០:០០:០០ ត្រូវនឹង ៥$^{៣}/_{៤}$ បាវ ជីអ៊ុយរ៉េ ២៦៣ គ.ក)។ ការប្រើកម្រិតខ្ពស់នៃជីអាសូតបែបនេះលើដំណាំស្រូវដែលមានការគ្រប់គ្រងទឹកបានល្អ អាចទទួលបានទិន្នផលខ្ពស់។ ក្នុងរយៈពេល ៤ ទៅ ៥ ឆ្នាំ ក្រោយពីការប្រើជីអាសូតខ្ពស់នឹងមានការឆ្លើយតបទៅនឹងជីផូស្វ័រ ជាពុំខាន (គឺ ១៨០:៤៥:០០ ត្រូវនឹង ៧ បាវ នៃជីអ៊ុយរ៉េ និង ២ បាវ នៃជី DAP)។

នៅរដូវវស្សាពូជស្រូវប្រពៃណីដែលដាំនៅលើដីប្រភេទនេះ ច្រើនជាពូជស្រូវឡើងទឹក ហើយពុំមានការចំណេញពីការពីការប្រើប្រាស់ជីទេ។

ក្រុមដីក្រគរ (Krakor)

១២០:២៥:០០ ***ពូជស្រូវទំនើប*** ត្រូវនឹងជីអ៊ុយរ៉េ ៤$^{៣}/_{៤}$ បាវ (ឬ ២៣៨ គ.ក) និង DAP មួយបាវ។

ដីក្រុមនេះមានជីវជាតិល្អ ហើយមានការឆ្លើយតបទៅនឹងការប្រើជីអាសូត លើដំណាំស្រូវប្រាំង ឬស្រូវប្រដេញទឹក។ ជាទូទៅប្រភេទដីនេះ មានការឆ្លើយតបទៅនឹងការប្រើជីអាសូត និងជីផូស្វ័រ នៅលើដំណាំស្រូវប្រាំង ឬស្រូវប្រដេញទឹក។ គេអាចទទួលបានផលខ្ពស់ កាលណាគេបាចជីអាសូត ក្នុងកម្រិតខ្ពស់ទៅលើដំណាំស្រូវប្រាំង ដែលពឹងផ្អែកទាំងស្រុងលើការស្រោចស្រព។ ក្រោយពីមានការប្រើជីអាសូត ក្នុងកម្រិតខ្ពស់អស់រយៈពេលប្រហែល ៤ ទៅ ៥ ឆ្នាំ ក្រោយមកគេនឹងសង្កេតឃើញមានការឆ្លើយតបទៅនឹងការប្រើជី (គឺ ១៨០:៤៥:០០ ត្រូវនឹងជីអ៊ុយរ៉េ ៧ បាវ និងជី DAP ២ បាវ)។ នៅរដូវវស្សាពូជប្រពៃណី ដែលដាំនៅលើដីប្រភេទនេះច្រើនជាស្រូវឡើងទឹក ហើយពុំមានការចំណេញពីការប្រើប្រាស់ជីទេ។

ក្រុមដីក្បៀនស្វាយ (Kean Svay)

៥៤:០០:០០ ***ពូជស្រូវទំនើប*** ត្រូវនឹងជីអ៊ុយរ៉េ ២ បាវកន្លះ។

Cambodian Agricultural Research and Development Institute (CARDI)

ដីក្រុមនេះមានជីវជាតិល្អ ហើយមានការឆ្លើយតបទៅនឹងការប្រើជីអាសូតលើដំណាំស្រូវប្រាំងឬ ស្រូវប្រដេញទឹក។ ពេលវេលាសមស្របសម្រាប់បាចជីអាសូតគឺក្នុងដំណាក់កាលស្រូវបែកគុម្ពអតិបរិមា ហើយអាចទទួលបានទិន្នផលខ្ពស់រហូតដល់ ៥.០២ តោនក្នុងមួយហិចតា។

Cambodian Agricultural Research and Development Institute (CARDI)

# បម្រើបម្រាស់ "អាសូត" ក្នុងផលិតកម្មដំណាំស្រូវ

**នៅ**ប្រទេសកម្ពុជាយើង ដំណាំស្រូវត្រូវការស្រូបយកអាសូត (N) សុទ្ធ ប្រហែល ១៦,៨ គ.ក្រ ដើម្បីផលិតគ្រាប់ស្រូវ ១០០០ គ.ក្រ។ ដូច្នេះដើម្បីផ្តល់ទិន្នផលចន្លោះពី ១,៥ ទៅ ២ ត/ហ.ត ដំណាំស្រូវនឹងត្រូវការស្រូបយកអាសូត ប្រហែល ២៥ ទៅ ៣០ គ.ក្រ/ហ.ត។ ការផ្តល់អាសូតពីធម្មជាតិ ដូចជាពីដី ពីទឹកស្រោចស្រព ពីទឹកភ្លៀង និងពីសកម្មភាពរបស់ពពួកមីក្រូសារពាង្គកាយ គឺនៅចន្លោះប្រហែលពី ៣០ ទៅ ៦០ គ.ក្រ/ហ.ត។ មិនមែនគ្រប់អាសូតទាំងអស់ក្នុងដីសុទ្ធតែមានភាពសេរីអាចឲ្យដំណាំស្រូវយកបានទេ។ អាសូតខ្លះ ត្រូវបានបាត់បង់តាមការធ្វើនីត្រាតកម្ម-ដេនីត្រាតកម្ម ការជ្រាបចុះ ការហូរចេញ ការស្រូបយករបស់ស្មៅ ឬដោយពពួកមីក្រូសារពាង្គកាយក្នុងដី។

**ប្រភេទ**ដីខ្សាច់ ច្រើនមានបរិមាណសារធាតុសរីរាង្គតិច ហើយច្រើនស្ថិតនៅតំបន់ទំនាបអាស្រ័យរបបទឹកភ្លៀង រីឯប្រភេទដីល្បាប់ចាស់ ដែលសម្បូរណ៍ដោយសារធាតុសរីរាង្គ ស្ថិតនៅក្នុងដីទំនាបលិចទឹកសកម្ម។ ការកើនឡើងនៃទិន្នផលតាមកម្រិតកំណត់នោះ មិនអាចទទួលបានឡើយប្រសិនបើមិនប្រើជីអាសូតតាមរយៈជីគីមី ឬជីសរីរាង្គទេនោះ។

**ដើម្បី**ប្រើប្រាស់ជីឲ្យមានប្រសិទ្ធភាព និងលក្ខណៈសេដ្ឋកិច្ចខ្ពស់ ក្នុងការបង្កើនទិន្នផលស្រូវគប្បីពិចារណានូវកត្តាសំខាន់ៗមួយចំនួនដូចខាងក្រោម៖

## អ្វីដែលជាកត្តាកំណត់ទិន្នផល?

**ជី**អាសូតមិនអាចជំនួសមុខឲ្យកង្វះខាតទឹក ឬកង្វះខាតសារធាតុចិញ្ចឹមផ្សេងៗទៀតដូចជាផូស្វ័រ (P) និង ប៉ូតាស្យូម (K) បាននោះទេ។ នៅក្នុងឆ្នាំដែលមានភាពរាំងស្ងួត ទិន្នផលស្រូវមិនត្រូវបានកំណត់ដោយសារធាតុអាសូត នោះទេ ហើយការបាចជីអាសូតបន្ថែម នឹងមិនអាចបង្កើនទិន្នផលបានទេ។

**ក្នុង**ករណីជាច្រើន អាសូតគឺជាសារធាតុចិញ្ចឹមសំខាន់របស់រុក្ខជាតិ។ ប៉ុន្តែពេលខ្លះសារធាតុ P ឬក៏សារធាតុចិញ្ចឹមផ្សេងៗទៀត អាចកំណត់ការលូតលាស់របស់រុក្ខជាតិខ្លាំងជាងសារធាតុ N ទៅទៀត។ ការបន្ថែមជីអ៊ុយរ៉េ ដោយគ្មានដាក់ធាតុ P ទៅលើប្រភេទដីជាច្រើនក្នុងប្រទេសកម្ពុជា មិនអាចបង្កើនទិន្នផលឡើយ។ គួរចងចាំថាអាសូត គួរតែបាចជានិច្ចកាលក្នុងសមាមាត្រភាពលំនឹងមួយ ជាមួយសារធាតុចិញ្ចឹមផ្សេងៗទៀត ឬកត្តាផ្សេងៗដែលកំណត់ការដុះលូតលាស់របស់ដំណាំយ៉ាងខ្លាំងក្លានោះ។




## តើគួរបាចជីអាសូតក្នុងទម្រង់ដូចម្តេច?

**ធាតុ**អាសូតក្នុងទម្រង់ជាសារធាតុសរីរាង្គដែលរលួយល្មម គឺជាប្រភពអាសូតដ៏ល្អប្រសើរ។ សារធាតុសរីរាង្គបែបនេះរួមមាន ជីធម្មជាតិ ជីស្រស់ និងកាកសំណល់រុក្ខជាតិលេគុយមីណឺ។ ជីសរីរាង្គមានមាឌ និងទ្រង់ទ្រាយធំសំពីងសំពោង ហើយមានបរិមាណអាសូតទាប ធ្វើឲ្យលំបាកក្នុងការដឹកជញ្ជូន ដោយត្រូវចំណាយពេលវេលា កម្លាំងពលកម្ម និងថវិការច្រើន។ កាកសំណល់ខ្លះនៃរុក្ខជាតិលេគុយមីណឺ រលួយយ៉ាងឆាប់រហ័សក្រោយពេលបង្កប់វាទៅក្នុងដី ដែលជាហេតុនាំឲ្យវាបញ្ចេញអាសូតបានឆាប់ ហើយធាតុអាសូតដ៏តិចតួចដែលរលាយយឺតៗ ត្រូវបានដំណាំប្រើប្រាស់នៅក្នុងរដូវដាំដុះនោះ។



Cambodian Agricultural Research and Development Institute (CARDI)

អាសូតក្នុងដីគឺមីច្រើនមានទម្រង់ជាអាម៉ូញ៉ូម ($NH_4^+$) ឬនីត្រាត ($NO3^-$)។ សម្រាប់ស្រែលិចទឹក ដីអាសូតក្នុងទម្រង់ជា $NH_4^+$ (ជីអ៊ុយរ៉េ) មានការបាត់បង់តិចជាងក្នុងទម្រង់ជា $NO3^-$។ ដូច្នេះ សម្រាប់ដំណាំស្រូវ គួរបាចជីអាសូតក្នុងទម្រង់ជា $NH_4^+$។ ជីគីមីមានលក្ខណៈងាយស្រួលប្រើប្រាស់គ្រប់គ្រងនិងដឹកជញ្ជូន ប៉ុន្តែអាចមានការបាត់បង់ច្រើននៅពេលដែលការគ្រប់គ្រង និងប្រើប្រាស់វាមិនបានសមស្រប។




## តើគួរបាចជីអាសូតក្នុងបរិមាណប៉ុន្មាន?

កម្រិតអាសូតត្រឹមត្រូវសម្រាប់បាចអាស្រ័យទៅលើប្រភេទដី ពូជ (ទំនើប ឬប្រពៃណី) ប្រព័ន្ធផលិតកម្ម (ស្លង ឬពង្រោះ) រដូវកាល (រដូវប្រាំង ឬរដូវវស្សា) និងអាយុកាលរបស់ដំណាំ (ស្រូវស្រាល កណ្តាល ឬធ្ងន់)។ កម្រិតជីដ៏ល្អបំផុតសម្រាប់បាចគឺ អាស្រ័យផងដែរទៅលើតម្លៃជី និងតម្លៃស្រូវ។ កត្តាទាំងអស់នេះនឹងមានឥទ្ធិពលទៅលើទិន្នផលដែលទទួលបាន។ បច្ចុប្បន្ននៅប្រទេសកម្ពុជា មិនទាន់មានព័ត៌មានគ្រប់គ្រាន់ ដើម្បីព្យាករណ៍ឲ្យបានត្រឹមត្រូវនូវកម្រិតជីសមស្រប ដោយផ្អែកលើកត្តាទាំងអស់នោះឡើយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អនុសាសន៍នៃការប្រើប្រាស់ជី ដែលបានផ្សព្វផ្សាយកន្លងមក ធ្វើឲ្យការព្យាករណ៍កម្រិតជីដែលត្រូវប្រើប្រាស់សម្រាប់ដំណាំស្រូវ ដែលដាំនៅក្នុងមជ្ឈដ្ឋានមួយមានភាពជាក់លាក់។ អនុសាសន៍នេះ អាចរកបាននៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)។



## តើពេលវេលាណាដែលល្អបំផុតដើម្បីបាចជីអាសូត?

ការបាចអាសូត ត្រូវផ្សារភ្ជាប់ទៅនឹងសេចក្តីត្រូវការនៃដំណាក់កាលនីមួយៗរបស់ដំណាំ។ តម្រូវការអាសូត មានជាប់ជាប្រចាំនៅគ្រប់ដំណាក់កាលលូតលាស់របស់ដំណាំ។ នៅក្នុងដំណាក់កាលបែកគុម្ព គឺជាពេលវេលាមួយដែលតម្រូវការអាសូតមានកម្រិតខ្ពស់ ដូច្នេះកង្វះអាសូតនៅដំណាក់កាលនេះ ធ្វើឲ្យចំនួនដើមបែក និងចំនួនកួរថយចុះ ជាហេតុនាំឲ្យទទួលបានទិន្នផលទាប។ នៅចន្លោះដំណាក់កាលកំណរកំណើតកួរ និងចេញផ្កា ក៏ជាពេលវេលាមួយដែលតម្រូវការអាសូតមានកម្រិតខ្ពស់ដែរ ហើយប្រសិនបើមានកង្វះអាសូតនៅដំណាក់កាលនេះ វានឹងបន្ថយនូវចំនួនគ្រាប់ដាក់ក្នុងមួយគួរ ឬប្រសិនបើកង្វះ N កើតមាននៅក្នុងដំណាក់កាលគ្រាប់ដាក់ទឹកដោះ នោះទម្ងន់គ្រាប់នឹងធ្លាក់ចុះ។ ការបាចជី N ហួសកម្រិត ក្នុងវគ្គលូតលាស់របស់ដំណាំស្រូវ អាចបង្កឲ្យមានស្លឹកច្រើនហួស និងដើមខ្ពស់។ បញ្ហានេះនឹងធ្វើឲ្យមានការដួលដើម និងបន្ថយការធ្វើរស្មីសំយោគ ហើយបណ្តាលឲ្យទិន្នផលស្រូវថយចុះ។

ការបាចជីអាសូតរំលែកជាបីដងនៅក្នុងវដ្តជីវិតរបស់ដំណាំស្រូវ បង្កើនទិន្នផលជាងការបាចតែមួយដង ឬពីរដង។ នៅក្នុងមជ្ឈដ្ឋានដាំដុះអាស្រ័យលើរបបទឹកភ្លៀង ការបាចជីអាសូតបំបែកមានអត្ថប្រយោជន៍បន្ថែមទៀតក្នុងការគ្រប់គ្រងជីអាសូតឲ្យបានល្អតាមកាលៈទេសៈ និងសម្រួលដល់ការបាចជីអាសូតបំប៉ន នៅពេលដែលមានលក្ខខណ្ឌល្អប្រសើរ។ តារាងខាងក្រោមបង្ហាញពីពេលវេលាសមស្របសម្រាប់ការបាចជីអាសូតតាមកម្រិតណែនាំនៅរដូវប្រាំង និងរដូវវស្សា។

Cambodian Agricultural Research and (CARDI)

| ប្រភេទនៃដំណាំស្រូវ | ស្រូវសន្ទូង | | | ស្រូវពង្រោះ | | |
|---|---|---|---|---|---|---|
| | បាចមុនពេលស្ទូង | បាច ៣០ ថ្ងៃក្រោយស្ទូង | បាចពេលកំណរកំណើតកួរ | បាចនៅពេលព្រោះគ្រាប់ | បាច ៥០ ថ្ងៃក្រោយព្រោះ | បាចពេលកំណរកំណើតកួរ |
| ស្រូវស្រាល | ៥០ % | 0 | ៥០ % | ៥០ % | 0 | ៥០ % |
| ស្រូវកណ្តាល | ៣០ % | ៥០ % | ៣០ % | ៣០ % | ៥០ % | ៣០ % |
| ស្រូវធ្ងន់ | ៣០ % | ៥០ % | ៣០ % | ៣០ % | ៥០ % | ៣០ % |

**តើត្រូវបាចអាសូតដូចម្តេច?**

**ការស្រាវជ្រាវបានបង្ហាញថា** បរិមាណអាសូតច្រើនជាង ៥០ ភាគរយ ត្រូវបានបាត់បង់តាមរយៈនីត្រាតកម្ម-ដេនីត្រាតកម្ម នៅពេលដែលបាចវាទៅក្នុងទឹក។ ការបាត់បង់អាសូតមានកម្រិតខ្ពស់ដូចគ្នា ប្រសិនបើដីនោះជួបគ្រោះរាំងស្ងួត ហើយបន្ទាប់មកលិចទឹកសារជាថ្មី។

**ដីនៅប្រទេសកម្ពុជាដែលមានសមត្ថភាពដោះដូរកាចុង (CEC) ទាប** បរិមាណអាសូតដ៏ច្រើន អាចនឹងត្រូវបានបាត់បង់តាមការជ្រាបចុះក្រោម និងតាមការហូរចេញ កាលណាគេបាចវានៅដើមរដូវ។ គេអាចបន្ថយការបាត់បង់អាសូត បានមួយភាគធំ កាលណាគេបង្កប់វាទៅក្នុងដីក្នុងស្រទាប់រេដុកកម្មនៃដី (ក្រោមជម្រៅ ៥ ស.ម) និងប្រសិនបើគេបាចអាសូត ក្រោយពេលដែលដីលិចទឹករួច ឬក្រោយបង្កប់សារធាតុសរីរាង្គរួចហើយ។ ការបង្កប់ជីអ៊ុយរ៉េ ទម្រង់ជាគ្រាប់ក៏បន្ថយការបាត់បង់អាសូតគួរឲ្យកត់សម្គាល់ដែរ ប៉ុន្តែទាំងជី ទាំងការអនុវត្តន៍អាចមានការលំបាកចំពោះលក្ខខណ្ឌប្រទេសកម្ពុជានាបច្ចុប្បន្ន។

**សម្រាប់ស្រែទំនាបអាស្រ័យលើរបបទឹកភ្លៀង** ជាពិសេសក្រុមដីព្រៃខ្មែរ ប្រទះឡាង បាកាន និងអូរៀង ត្រូវបង្កប់ជីសរីរាង្គទៅក្នុងដីឲ្យបានពី ៣ ទៅ ៤ សប្តាហ៍ មុនពេលធ្វើការដាំដុះ។ គួរបាចជីអ៊ុយរ៉េ បង្កប់ភ្លាមៗទៅក្នុងដី រួចពន្លិចទឹកមុនពេលស្ទូង ឬព្រោះគ្រាប់។ ប្រសិនបើមានភ្លៀង ហើយទឹកហូរឆ្លងកាត់ពីស្រែមួយទៅស្រែមួយទៀត ចូរកុំបាចជីឲ្យសោះ ហើយរងចាំរហូតដល់ទឹកឈប់ហូរ។ នៅក្នុងលក្ខខណ្ឌដែលមានការគ្រប់គ្រងទឹកបានល្អ (ស្រែស្រោចស្រពរដូវប្រាំង) គួរបង្ហូរទឹកចេញឲ្យអស់ពីក្នុងស្រែ ហើយបាចជី N ដោយបង្កប់ទៅក្នុងដី រួចបញ្ចូលទឹកសារជាថ្មី។

Cambodian Agricultural Research and Development Institute (CARDI)

# ការពុលជាតិដែកលើដំណាំស្រូវ

ការពុលដែកបណ្តាលមកពីរុក្ខជាតិស្រូបយកធាតុដែកច្រើនពេកពីក្នុងសូលុយស្យុងដី ដែលសម្បូរទៅដោយដែករលាយ ($Fe^{2+}$)។ ការស្រូបយកធាតុដែកច្រើនបានជំរុញនូវសកម្មភាពនៃការធ្វើអុកស៊ីតកម្មរបស់ប៉ូលីហ្វេណុល (Polyphenol) ហើយដែលការនេះបណ្តាលឲ្យស្លឹកស្រូវប្រែពណ៌ទៅជាលឿងទុំ។ ការពុលដែកក៏ទាក់ទិនផងដែរទៅនឹងភាពមិនប្រក្រតីនៃសារធាតុចិញ្ចឹមច្រើនមុខ ដែលធ្វើឲ្យកម្រិតធ្វើអុកស៊ីតកម្មរបស់ឫសធ្លាក់ចុះ ព្រោះថាការធ្វើអុកស៊ីតកម្មនៃឫស ជួយកាត់បន្ថយកម្រិតដែករលាយក្នុងសូលុយស្យុងដី។

## ១. បុព្វហេតុដែលបណ្តាលឲ្យមានការពុលដែក

ការពុលដែកអាចបណ្តាលមកពីបុព្វហេតុសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- មានកំហាប់អ៊ីយ៉ុងដែក $Fe^{2+}$ ច្រើននៅក្នុងដីបណ្តាលមកពីដីមាន pH ទាប ហើយធ្វើរេដុកម្មដ៏ខ្លាំងក្លាក្នុងពេលវាលិចទឹក។
- មានសារធាតុចិញ្ចឹមមិនគ្រប់គ្រាន់ និងគ្មានតុល្យភាពនៃសារធាតុចិញ្ចឹមក្នុងដី។ កង្វះសារធាតុចិញ្ចឹមផូស្វ័រ (P) កាល់ស្យូម (Ca) មាញ៉េស្យូម (Mg) ឬប៉ូតាស្យូម (K) ធ្វើឲ្យកម្រិតអុកស៊ីតកម្មនៃឫស និងកម្លាំងនៃការច្រានចោលអ៊ីយ៉ុងដែក $Fe^{2+}$ ចុះខ្សោយ។ កង្វះ K ច្រើនទាក់ទិននឹងដីដែលមានបរិមាណបាស និងតម្លៃ pH ទាប ហើយដែលកត្តាទាំងនេះ វាមានទំនាក់ទំនងជាមួយនឹងកំហាប់ដែកខ្ពស់នៅក្នុងដី។
- កម្រិតអុកស៊ីតកម្មនៃឫសខ្សោយ ដោយសារតែនៅក្នុងតំបន់ឫស (Rhizosphere) សម្បូរទៅដោយសារធាតុអ៊ីដ្រូសែនស៊ុលភួ ($H_2S$) ដែកស៊ុលភីត (FeS) និងអាស៊ីតសរីរាង្គ ដែលជាសារធាតុរារាំងដល់ដំណកដង្ហើមរបស់ឫសស្រូវ។
- មានការប្រើប្រាស់កាកសំណល់ធាតុសរីរាង្គជាច្រើន ដែលមិនទាន់រលួយពេញលេញ។
- ការផ្តល់ជាបន្តបន្ទាប់នូវធាតុដែកចូលទៅក្នុងដី តាមរយៈទឹកក្រោមដី ឬការជ្រាបចេញពីភ្នំ។
- ការប្រើប្រាស់ទឹកស្អុយ ឬកាកសំណល់ឧស្សាហកម្មដែលមានផ្ទុកជាតិដែកខ្ពស់។

## ២. រោគសញ្ញានៃការពុលដែក

រោគសញ្ញានៃការពុលដែកនេះ ដំបូងលេចចេញនូវអុចតូចៗ ពណ៌ត្នោតនៅលើផ្ទៃស្លឹកទាបៗជាងគេ ហើយអុចតូចៗទាំងនេះ ចាប់ផ្តើមរាលដាលពីចុងស្លឹក ឬកើតពាសពេញផ្ទៃស្លឹកទាំងមូល។ បន្ទាប់មកអុចទាំងនោះក៏រាលដាលពេញផ្ទៃស្លឹកធ្វើឲ្យស្លឹកមានពណ៌លឿងត្នោត រួចក៏ងាប់ជាបន្តបន្ទាប់។ ស្លឹកមានសភាពតូច ហើយនៅតែរក្សាភាពបៃតងដដែល។ ក្នុងករណី ដែលមានការពុលដែកខ្លាំង ស្លឹកទាំងឡាយប្រែជាពណ៌ត្នោតស្វាយ។ ចំពោះពូជខ្លះ ចុងស្លឹកមានពណ៌លឿងទុំហើយស្ងួត។ ការលូតលាស់ និងការបែកគុម្ពក៏ថយចុះ រីឯប្រព័ន្ធឫសស្រូវក៏ឡើងគ្រោតគ្រាត មិនដុះចេញច្រើន ហើយមានពណ៌ត្នោតចាស់ទៅក្រមៅ។ រោគសញ្ញានៃការពុលដែក អាចកើតឡើងក្នុងអំឡុងពេលពី ១-២ សប្តាហ៍ក្រោយស្ទូង ប៉ុន្តែជួនកាលវាក៏អាចកើតឡើង ២ ខែ ក្រោយស្ទូងផងដែរ អាស្រ័យទៅតាមប្រភេទដី។





Cambodian Agricultural Research and Development Institute (CARDI)

## ៣. តើការពុលដែកកើតលើដីអ្វីខ្លះ?

ការពុលដែកកើតឡើងនៅលើដីច្រើនប្រភេទ ប៉ុន្តែជាទូទៅ វាកើតនៅលើដីដំណាំស្រូវនៃតំបន់ទំនាបដែលលិចទឹកជាអចិន្ត្រៃយ៍ក្នុងរដូវកាលដាំដុះ។ លក្ខណៈសម្គាល់ទូទៅនៃកន្លែងដែលមានការពុលដែក គឺដីដែលមានការដក់ទឹកជាប្រចាំ ដីដែលមានសមត្ថភាពបណ្តូរកាចុងទាប និងដីដែលមានបរិមាណម៉ាក្រូធាតុ (N, P, K,...) ទាប។ ការពុលដែកកើតឡើងនៅលើដីដែលមាន pH ពី ៤-៧។



**ប្រភេទ**ដីដែលងាយទទួលរងនូវការពុលដែកមានដូចជា៖ ដីនៃតំបន់ជ្រលងភ្នំដែលមានការដក់ទឹកយូរ ហើយដែលទទួលនូវរំហូរពីដីអាស៊ីតនៃតំបន់ខ្ពង់រាប ដីកាអូលីនីត (Kaolinite) ដែលមានសមត្ថភាពបណ្តូរកាចុងទាប និងមានបរិមាណ P និង K តិចតួច ដីល្បាប់ឥដ្ឋ អាស៊ីត ដីអាស៊ីតសុលផាតក្មេង ដីអាស៊ីតតំបន់ទំនាប ឬវាលល្បាប់ខ្ពស់ដែលសម្បូរទៅដោយសារធាតុសរីរាង្គ។

## ៤. វិធានការបង្ការការពុលដែក

ការប្រើវិធីសាស្ត្រក្នុងការគ្រប់គ្រង និងការបង្ការការពុលដែកជាមធ្យោបាយដ៏ប្រសើរមួយ ព្រោះថាការព្យាបាលការពុលដែកក្នុងអំឡុងពេលដាំដុះដំណាំមានការលំបាកណាស់។វិធានការដើម្បីបង្ការការពុលដែកមានដូចខាងក្រោម៖

- *ពូជ៖* ប្រើពូជស្រូវដែលធន់នឹងភាពពុលដែក។ ពូជស្រូវអ៊ីប្រ៊ីត (Hybrid) ដែលមានប្រព័ន្ធឫសលូតលាស់ខ្លាំង ហើយឫសមានកម្លាំងធ្វើអុកស៊ីតកម្មខ្លាំង មានភាពធន់ទៅនឹងការពុលដែក ប្រសិនបើបាចជីជាតិបានគ្រប់គ្រាន់។
- *គ្រប់គ្រងការដាំដុះ៖* ពន្យាពេលដាំដុះដំណាំ រហូតដល់ផុតពេលដែលកំហាប់នៃដែករលាយ ($Fe^{2+}$) ឡើងដល់កំពូល បានន័យថា គួរដាំដំណាំក្នុងរយៈពេល ១០-២០ ថ្ងៃ ក្រោយពេលដីលិចទឹក។
- *គ្រប់គ្រងទឹក៖* ចៀសវាងការពន្លិចទឹកជាប្រចាំ ចំពោះដីដែលមានបរិមាណសារធាតុសរីរាង្គច្រើន និងកំហាប់ដែកខ្ពស់។ អនុវត្តការបង្ហូរទឹកចេញនៅពាក់កណ្តាលរដូវកាលដាំដុះ ដើម្បីជួយការកាត់បន្ថយបរិមាណ $Fe^{2+}$ នៅក្នុងដី។ នៅពាក់កណ្តាលដំណាក់កាលបែកគុម្ព (២៥-៣០ថ្ងៃ ក្រោយស្ទូង ឬព្រោះ) ត្រូវបង្ហូរទឹកចេញពីស្រែឲ្យអស់ ដោយគ្រាន់តែទុកដីឲ្យនៅសើមរយៈពេល ៧-១០ថ្ងៃ ដើម្បីផ្គត់ផ្គង់អុកស៊ីសែន ($O_2$) នៅដំណាក់កាលបែកគុម្ព។
- *គ្រប់គ្រងជីជាតិដី៖* ធ្វើឲ្យមានតុល្យភាពនៃការប្រើជីជាតិ NPK ឬ NPK + កំបោរ ដើម្បីចៀសវាងភាពមិនប្រក្រតីនៃសារធាតុចិញ្ចឹមរបស់ដំណាំ។ ប្រើជី K ឲ្យបានគ្រប់គ្រាន់ ឬបាចកំបោរទៅលើដីអាស៊ីត ប្រើជីអ៊ុយរ៉េ ប្រសើរជាងជីអាម៉ូញ៉ូមស៊ុលផាត។
- *គ្រប់គ្រងដី៖* អនុវត្តការភ្ជួរដីហាលបន្ទាប់ពីប្រមូលផលរួច ដើម្បីបង្កើនការធ្វើអុកស៊ីតកម្មនៃដែក ($Fe^{2+}$) ក្នុងពេលដីនៅទំនេរ។ ការនេះជួយកាត់បន្ថយកំណើននៃដែក ($Fe^{2+}$) ដែលរលាយបន្ទាប់ពីមានការពន្លិចទឹកឡើងវិញ។

ព័ត៌មានបន្ថែមសូមទាក់ទង ការិយាល័យវិទ្យាសាស្ត្រដី និងទឹក មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា តាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ ទូរសារលេខ: (៨៥៥-២៣) ២១៩ ៨០០ គេហទំព័រ: www.cardi.org.kh
ទូរអក្ខរ: vseng@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh



Cambodian Agricultural Research and Development Institute (CARDI)

# ការពុលជាតិប្រៃលើដំណាំស្រូវ

គឺជាបរិមាណនៃកំហាប់អំបិលដែលកើតមានឡើងនៅក្នុងសូលុយស្យុងដី។ កាលណាកម្រិតអំបិលកើនឡើងខ្លាំងនៅក្នុងសូលុយស្យុងដី អាចធ្វើឲ្យមានការបាត់បង់នូវតុល្យភាពរបស់សារធាតុចិញ្ចឹមក្នុងសូលុយស្យុងដី ដែលជាហេតុបណ្តាលឲ្យមានការពុលសារធាតុចិញ្ចឹមចំពោះដំណាំ និងធ្វើឲ្យដំណាំពិបាកស្រូបយកទឹកពីសូលុយស្យុងដី។ សូដ្យូម (Na) មាញ៉េស្យូម (Mg) កាល់ស្យូម (Ca) ស្ពាន់ធ័រ (S) និងក្លរ (Cl) គឺជាសារធាតុដ៏សំខាន់ក្នុងការចូលរួមរាល់សកម្មភាពទាំងនេះ។ បញ្ហាចម្បងនៃការពុលជាតិប្រៃលើដំណាំស្រូវ គឺកើតមានឡើងនៅពេលដែលដំណាំស្រូវស្រូបយកអ៊ីយ៉ុង សូដ្យូម (Na) ដ៏ច្រើនលើសលុបពីសូលុយស្យុងដី ដែលមានកង្វះសារធាតុប៉ូតាស្យូម (K) និងកាល់ស្យូម (Ca) ដែលជាហេតុបណ្តាលឲ្យដំណាំមានកង្វះសារធាតុប៉ូតាស្យូម (K) និងកាល់ស្យូម (Ca) កាន់តែខ្លាំងឡើង។ ប្រសិនបើបរិមាណប៉ូតាស្យូម និងកាល់ស្យូម មានការថយចុះនៅក្នុងដំណាំ អាចធ្វើឲ្យមានការកើនឡើងនូវសារធាតុអាម៉ូនីញ៉ូមនីទ្រីត សូដ្យូម ស្ពាន់ធ័រ និង ក្លរ ដែលងាយបង្កឲ្យមានការពុលដល់ដំណាំស្រូវ។

## ១.ប្រភពនៃដីប្រៃ

ដីប្រៃកើតមានឡើងដោយកត្តាសំខាន់ៗរួមផ្សំជាច្រើនដូចខាងក្រោម៖

- ការប្រើប្រាស់ជីគីមីពុំសមស្របតាមកម្រិតណែនាំរបស់អ្នកបច្ចេកទេសកសិកម្ម ឬពុំសមស្របតាមសេចក្តីត្រូវការរបស់ប្រភេទដំណាំ អាចបណ្តាលឲ្យមានការលើសនូវសារធាតុចិញ្ចឹមក្នុងសូលុយស្យុងដី។
- ការប្រើប្រាស់ជីប្រភេទម្នាងសិលា (Gypsum: $CaSO_4$) អាចបណ្តាលឲ្យមានការលើសធាតុកាល់ស្យូម (Ca) និងស្ពាន់ធ័រ (S)។
- ការប្រើប្រាស់កាកសំណល់ធាតុសរីរាង្គជាច្រើនដែលពុំទាន់រលាយសមស្របល្អសម្រាប់ដំណាំ។
- ការផ្តល់នូវធាតុប្រៃតាមរយៈប្រព័ន្ធស្រោចស្រពដែលមានប្រភពទឹកក្រោមដី ឬការជ្រាបចេញពីភ្នំ ដែលសម្បូរទៅដោយ Na, Mg, Ca, S និង Cl។
- ការបាចអំបិលសមុទ្រ (NaCl) លើស្រែដាំដុះដំណាំស្រូវ ឬដីស្រែដែលមានទឹកសមុទ្រហូរចូល។
- ការផ្តល់នូវធាតុប្រៃតាមរយៈនៃការពុកផុយថ្មកំបោរ ឬសិលារ៉ែមួយចំនួនក្រោមអំពើនៃការសឹករិចរឹលដោយធាតុអាកាស។ សារធាតុដែលបង្ករជាជាតិប្រៃនៅក្នុងសូលុយស្យុងដីទាំងនេះ អាចហូរចូលទៅស្រទាប់ទឹកក្រោមដីតាមរយៈការហូរច្រោះនៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង ឬការស្រោចស្រពលើសសេចក្តីត្រូវការទឹករបស់ដំណាំ។

## ២. មូលហេតុដែលបណ្តាលអោយមានការពុលជាតិប្រៃ

ការពុលជាតិប្រៃលើដំណាំស្រូវច្រើនកើតមានឡើងនៅតំបន់ស្រែទំនាបអាស្រ័យលើរបបទឹកភ្លៀង ដែលជាប្រភេទដីខ្សាច់ ងាយស្រួលក្នុងការហូរច្រោះ មានសមត្ថភាពបណ្តុរកាចុងទាប និងជាប្រភេទដីដែលខ្សត់ជីជាតិ។ ការពុលជាតិប្រៃកើតឡើងនៅពេលដែលស្រទាប់ទឹកក្រោមដី ដែលសម្បូរនូវសារធាតុប្រៃឡើងមកស្រទាប់ខាងលើនៃដីដែលជាស្រទាបឫសរបស់ដំណាំ។ នៅពេលដែលពុំមានភ្លៀងធ្លាក់គ្រប់គ្រាន់ ហើយដីមានរំហួតខ្លាំងធ្វើឲ្យដីស្រទាប់លើឆាប់ស្ងួត និងឆាប់ទទួលរងនូវការពុលជាតិប្រៃ ឬសារធាតុចិញ្ចឹមផ្សេងៗទៀតដែលបង្កឡើងដោយទឹកក្រោមដីនៅតំបន់ស្រទាប់ឫសរបស់ដំណាំ។ ការស្រោចស្រពដំណាំស្រូវដោយប្រព័ន្ធទឹកស្ទឹង ឬទឹកបឹងមិនស្អាតដែលមានកំហាប់អំបិលខ្ពស់ ឬប្រភពពីទឹកក្រោមដី អាចជាមូលហេតុបង្កឲ្យមានការពុលជាតិប្រៃចំពោះដំណាំស្រូវផងដែរ។ ម្យ៉ាងទៀតការបាចអំបិលដោយផ្ទាល់ទៅលើស្រែដាំស្រូវ ការប្រើជីសរីរាង្គដែលពុំទាន់រលាយល្អ អាចបង្កឲ្យមានការកើនឡើងខ្លាំងនូវសារធាតុអាម៉ូនីញ៉ូមនីទ្រីត សូដ្យូម និងស្ពាន់ធ័រ ដែលងាយបង្កឲ្យពុលដល់ដំណាំស្រូវ។

Cambodian Agricultural Research and Development Institute (CARDI)

## ៣. រោគសញ្ញានៃការពុលជាតិប្រៃលើដំណាំស្រូវ



រោគសញ្ញាដំបូងនៃការពុលជាតិប្រៃ គឺចុងស្លឹកមានពណ៌ស កើតមាននៅលើស្លឹកចាស់ៗ រាលដាលតាមគែមៗស្លឹកបន្ទាប់មកពាសពេញផ្ទៃស្លឹកទាំងមូល រួចរាលដាលទៅកាន់ស្លឹកខ្ចីៗផ្នែកខាងលើទៀត រួចងាប់ជាបន្តបន្ទាប់។ ក្នុងករណីមានការពុលជាតិអំបិលខ្លាំង មានការរំខានដល់ការដុះពន្លកដើមស្រូវ រំខានដល់ការលូតលាស់របស់ឫស បន្ថយនូវការលូតលាស់កម្ពស់ដើម បន្ថយចំនួនដើមបែក និងបង្កើនចំនួនគ្រាប់ស្កក។ រោគសញ្ញានៃការពុលជាតិអំបិល អាចកើតមានឡើងនៅវគ្គសំណាប វគ្គលូតលាស់ និងវគ្គបង្កើនផល។

## ៤. វិធានការគ្រប់គ្រង និងការបង្ការការពុលជាតិប្រៃ

ដើម្បីកាត់បន្ថយការពុលជាតិប្រៃទៅលើដំណាំស្រូវ គឺត្រូវធ្វើការទប់ស្កាត់កុំឲ្យទឹកស្រទាប់ក្រោមដីឡើងមកកាន់ស្រទាប់លើ ដែលជាស្រទាប់ឫសដំណាំ និងត្រូវប្រើបច្ចេកទេសនៃការប្រើប្រាស់ដី និងការគ្រប់គ្រងជីជាតិដីឲ្យបានត្រឹមត្រូវ។ ការប្រើវិធីសាស្ត្រគ្រប់គ្រង និងបង្ការជាមុន ជាមធ្យោបាយដ៏ប្រសើរសម្រាប់ទប់ស្កាត់ការពុលជាតិប្រៃលើដំណាំស្រូវ ពីព្រោះការបំបាត់ការពុលក្នុងអំឡុងពេលដំណាំលូតលាស់មានការលំបាកណាស់។ វិធានការទូទៅដើម្បីគ្រប់គ្រង និងបង្ការការពុលជាតិប្រៃមានដូចខាងក្រោម៖

- *ការគ្រប់គ្រងការដាំដុះ៖* ជាបឋមត្រូវធ្វើការគ្រប់គ្រងដីឲ្យមានស្ថេរភាពល្អ តាមរយៈការប្រើប្រាស់កម្រិតជីសមស្របទៅតាមតម្រូវការរបស់ដំណាំ និងការគ្រប់គ្រង pH របស់ដី។ ត្រូវធ្វើការកាត់បន្ថយនូវរយៈពេលនៃការទុកដីចោលទំនេរយូរ ដោយដាំដុះដំណាំឆ្លាស់ ឬដំណាំបង្វិលដើម្បីជួយបង្កើនទម្រង់ និងជីជាតិរបស់ដី។ មិនត្រូវធ្វើការភ្ជួររាស់ជ្រៅពេក ដែលអាចបណ្តាលឲ្យមានការហូរច្រោះសារធាតុចិញ្ចឹមទៅក្នុងស្រទាប់ក្រោម និងទឹកក្រោមដីងាយឡើងមកកាន់ស្រទាប់លើ ដែលជាស្រទាប់ឫសដំណាំ។
- *ពូជ៖* ប្រើប្រាស់ប្រភេទពូជដែលមានប្រព័ន្ធឫសរាក់ វគ្គលូតលាស់របស់វាមានរយៈពេលខ្លី និងជាប្រភេទពូជស្រូវដែលធន់ទៅនឹងការពុលជាតិប្រៃ។
- *ការគ្រប់គ្រងទឹក៖* ត្រូវធ្វើការពន្លិចទឹកស្រែពី ២ ទៅ ៤ សប្តាហ៍ មុនការស្ទូងស្រូវក្នុងស្រែ។ មិនត្រូវប្រើប្រាស់ទឹកស្ទឹង ឬទឹកបឹង ឬទឹកក្រោមដី ដែលមានកំហាប់អំបិលខ្ពស់សម្រាប់ស្រោចស្រពដីស្រែឡើយ។ បើដីមានជាតិប្រៃ ត្រូវធ្វើការពន្លិចទឹកស្រែបន្ទាប់ពីស្ទូងរួច ដើម្បីលាងជាតិប្រៃចេញពីសូលុយស្យុងដី។
- *ការគ្រប់គ្រងជីជាតិដី៖* ធ្វើឲ្យមានតុល្យភាពនៃការប្រើប្រាស់ជីអាសូត ជីផូស្វ័រ និងជីប៉ូតាស្យូម ដើម្បីចៀសវាងភាពមិនប្រក្រតីនៃសារធាតុចិញ្ចឹមរបស់ដំណាំ។ ការប្រើប្រាស់ជីប៉ូតាស្យូម ឲ្យបានគ្រប់គ្រាន់គឺមានសារៈសំខាន់ណាស់ ពីព្រោះវាធ្វើឲ្យមានការកើនឡើងនូវតម្លៃសមាមាត្ររបស់ប៉ូតាស្យូមធៀបនឹងសូដ្យូម (K:Na) ប៉ូតាស្យូមធៀបនឹងម៉ាញ៉េស្យូម (K:Mg) និងប៉ូតាស្យូមធៀបនឹងកាល់ស្យូម (K:Ca) នៅក្នុងដំណាំ។
- *ការគ្រប់គ្រងព្រៃបោះ៖* ចៀសវាងការកាប់បំផ្លាញព្រៃបោះដែលស្ថិតនៅតំបន់ខ្ពស់ជុំវិញវាលទំនាបដាំស្រូវ ដើម្បីការពារកុំឲ្យស្រទាប់ទឹកក្រោមដីងាយជ្រៀតឡើងមកស្រទាប់ដាំដុះ ដែលអាចបណ្តាលឲ្យមានការពុលដល់ដំណាំស្រូវ។

ព័ត៌មានបន្ថែមសូមទាក់ទង ការិយាល័យវិទ្យាសាស្ត្រដី និងទឹក មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា តាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ ទូរសារលេខ: (៨៥៥-២៣) ២១៩ ៨០០ គេហទំព័រ: www.cardi.org.kh
ទូរអក្ខរ: vseng@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh



Cambodian Agricultural Research and Development Institute (CARDI)

# ការធ្វើជីកំប៉ុស្តិ៍

**តើ**ជីលាមកសត្វ ផេះ ចំបើង ស្មៅ និងស្លឹករុក្ខជាតិមានសារធាតុអ្វីជារួម? គឺសារធាតុចិញ្ចឹមដែលត្រូវការចាំបាច់ណាស់សម្រាប់ដំណាំរបស់អ្នក។ ជីដែលបានពីរុក្ខជាតិកាកសំណល់សត្វពាហនៈ ត្រូវគេទទួលស្គាល់ថាជាជីសរីរាង្គ ដើម្បីឲ្យជីងាយនឹងផ្តល់នូវសារធាតុចិញ្ចឹមសម្រាប់ដំណាំនោះ គឺការធ្វើជីកំប៉ុស្តិ៍។ តើត្រូវធ្វើដោយរបៀបណា?

## ១. សារៈសំខាន់នៃការប្រើជីកំប៉ុស្តិ៍

- ជួយកែលម្អជីជាតិ និងផលិតភាពដី ដោយធ្វើឲ្យប្រសើរឡើងនូវលក្ខណៈរូបសាស្ត្រ ជីវសាស្ត្រ និងគីមីរបស់ដី។
- បន្ថយការប្រើប្រាស់ជីគីមី និងប្រាក់ចំណាយក្នុងការទិញជី
- ជួយបង្កើនទិន្នផល និងគុណភាពផលិតផលដំណាំ។
- ជួយជំរុញឲ្យជីគីមី មានប្រសិទ្ធភាពនៅពេលប្រើលាយជាមួយជីកំប៉ុស្តិ៍
- បន្ថយជាតិពុលនៃដី

## ២. កត្តាជាច្រើននាំមកនូវជោគជ័យក្នុងការធ្វើជីកំប៉ុស្តិ៍

**ជោគជ័យ**នៃការធ្វើជីកំប៉ុស្តិ៍ គឺការកើនឡើងនូវចំនួនសារធាតុចិញ្ចឹមនៅក្នុងដី ដែលសារធាតុទាំងនេះធ្វើឲ្យដំណាំលូតលាស់ល្អ និងផ្តល់ទិន្នផលខ្ពស់។ មានកត្តាជាច្រើននាំមកនូវជោគជ័យក្នុងការធ្វើជីកំប៉ុស្តិ៍គឺ៖

- ធាតុផ្សំសម្រាប់ធ្វើជីកំប៉ុស្តិ៍ ដូចជាលាមកសត្វ ដើមពោត ចំបើង ស្មៅ ស្លឹកឈើ និងផេះ
- ខ្យល់នៅក្នុងគំនរជីកំប៉ុស្តិ៍សមស្រប
- សំណើមនៃគំនរជីសមល្មម មិនជោគពេក ហើយក៏មិនស្ងួតពេកដែរ
- សីតុណ្ហភាព

**សារ**ធាតុចិញ្ចឹមនៃជីលាមកសត្វ កាកសំណល់រុក្ខជាតិ ក្នុងនោះរាប់បញ្ចូលទាំងកាកសំណល់ពពួកសណ្តែក និងលាមកសត្វពាហនៈ នៅក្នុងសារធាតុទាំងនោះមានបរិមាណសារធាតុចិញ្ចឹមច្រើនដែលត្រូវការដោយដំណាំ។ គួរចៀសវាងប្រើវត្ថុដែលមានសសៃៗ និងកំទេចឈើ ដូចជាដើមព្រលិត ដើមរុក្ខជាតិតូចៗដែលគេច្រើនដាំលម្អផ្ទះ ព្រោះរុក្ខជាតិទាំងនេះវាមិនងាយនឹងរលួយឡើយ។

ការដាក់ឲ្យត្រូវខ្យល់ ឬការធ្វើឲ្យមានខ្យល់ចេញចូលក្នុងគំនរជី គឺជាការចាំបាច់ក្នុងការធ្វើឲ្យជីឆាប់ផុយរលួយ ប្រការដែលគំនរជីគ្មានខ្យល់ចេញចូលនាំឲ្យជីបង្កើតឧស្ម័នពុល និងអាស៊ីតសរីរាង្គដែលផ្តល់ឥទ្ធិពលអាក្រក់ដល់ដំណាំ។



**គំនរ**ជីកំប៉ុស្តិ៍ត្រូវតែមានបរិមាណសំណើមសមស្របដែរ គំនរជីដែលមានសភាពសើមពេកនាំឲ្យជីហាប់ និងស្អិត តែបើគំនរជីនោះស្ងួតពេក ក៏នាំឲ្យជីមិនងាយផុយរលួយដែរ។

មានសីតុណ្ហភាពសមស្រប គឺជាសារៈប្រយោជន៍មួយដែរក្នុងការធ្វើជីកំប៉ុស្តិ៍ កាលណាគំនរជីមានសីតុណ្ហភាពខ្ពស់នាំឲ្យជីឆាប់ផុយរលួយល្អ ហេតុនេះវាជាការចាំបាច់ណាស់ដែរត្រូវរក្សាសីតុណ្ហភាពនៃគំនរជី។ ជាទូទៅកម្តៅនៃគំនរជីត្រូវកើន

Cambodian Agricultural Research and Development Institute (CARDI)

ឡើងក្នុងអំឡុងពេលពី ១ ទៅ ២ ថ្ងៃ កាលណាផ្នែកខាងក្នុងនៃគំនរជីមានកម្តៅ បានន័យថាភាពរលួយនៃជីកំប៉ុស្តកំពុងដំណើរការ។




## ៣. របៀបធ្វើជីកំប៉ុស្ត

**ជំបូង**ត្រូវប្រមូលវត្ថុធាតុដើមជីកំប៉ុស្ត អ្នកអាចប្រើលាមកសត្វពាហនៈ ដើមពោត ចំបើង ស្មៅ និងស្លឹកឈើ។ ត្រូវយកចេញវត្ថុណាដែលយើងដឹងថាមិនរលួយ ដូចជាសំបកកំប៉ុង ប្លាស្ទិច អំបែងកែវ ជាដើម។ កាប់ចិញ្ច្រាំចំបើង និងស្មៅ ដើម្បីឲ្យចរន្តខ្យល់ចេញចូលបានល្អ និងងាយរលួយ។ ត្រូវជ្រើសកន្លែងមានម្លប់ហើយទួលបន្តិចមិនដក់ទឹក និងគួរនៅជិតប្រភពទឹកផងនោះ ជាកន្លែងសមស្របសម្រាប់គំនរជីកំប៉ុស្តរបស់អ្នក។ ដោតបន្ទះឫស្សីចំណាំកន្លែងលើផ្ទៃដីមានទំហំ ២ ម X ៦ ម សម្អាតផ្លាក្បែរនោះឲ្យមានទំហំប៉ុនគ្នា ព្រោះអ្នកប្រើផ្លានោះចូកត្រលប់ជីកំប៉ុស្តរបស់អ្នក។ គរគំនរសំណល់រុក្ខជាតិឲ្យបានកម្ពស់ ១៥ ស.ម កៀរគំនរតែមិនត្រូវសង្កត់ ឬជាន់វាឡើយ។ គំនរនេះមិនត្រូវឲ្យហាប់ពេកទេ កម្ពស់ ៥ សង់ទីម៉ែត្រ ពីលើគំនរសំណល់រុក្ខជាតិ បន្ទាប់មកត្រូវចាក់ផេះ ឬកំបោរកម្រាស់ ២ សង់ទីម៉ែត្រ លើលាមកសត្វ អ្នកអាចដាក់បន្ថែមជីអ៊ុយរ៉េ ចំនួន ១ គីឡូក្រាម ឬអាម៉ូញ៉មស៊ុលផាត ឬក៏ស៊ុបពែផូស្វាត បន្តការរៀបគំនរ ដោយដាក់កាកសំណល់រុក្ខជាតិ លាមកសត្វ និងផេះ រហូតដល់គំនរនេះកម្ពស់បានពី ១ ម៉ែត្រទៅ ១,៥ ម៉ែត្រ។ ដើម្បីរក្សាសំណើម ត្រូវស្រោចទឹកលើគំនរនោះដោយប្រើធុងស្រោចដំណាំ។ ត្រូវស្រោចទឹកក្នុងកម្រិតមធ្យមធ្វើដូច្នេះទើបទឹកមិនហៀរពីគំនរ។







ចូកត្រលប់កំប៉ុស្តក្រោយរយៈពេល ៣ សប្តាហ៍ យកផ្នែកលើទៅក្រោម និងផ្នែកក្រោមទៅលើ ធ្វើដូច្នេះដើម្បីឲ្យខ្យល់ចូលបានល្អ និងអាចបង្កើតឲ្យជីឆាប់រលួយ។ ស្រោចទឹកបន្ថែមដើម្បីរក្សាគំនរជីឲ្យមានសំណើម។ ៥ សប្តាហ៍ក្រោយមកត្រូវចូកជីដាក់កន្លែងដើមវិញ ដើម្បីឲ្យកាន់តែប្រសើរត្រូវគ្របគំនរជី ដោយប្រើក្រណាត់ប្លាស្ទិក ឬក៏សម្បុកបាវ ត្រូវគ្របគំនរជីឲ្យជិត លើកលែងតែផ្នែកខាងក្រោមនៃគំនរជី ដើម្បីរក្សាកម្តៅ និងបន្ថយនូវរំហួតទឹក។ ទុកគំនរជីឲ្យរលួយក្នុងរយៈពេល ៤ សប្តាហ៍ នៅពេលជីអាចប្រើការបាន ជាទូទៅវាមានពណ៌ត្នោតចាស់ក្រមៅ ហើយមានសភាពដូចដី នៅពេលនេះអ្នកអាចប្រើជីកំប៉ុស្តដូចជាជីសរីរាង្គ។





Cambodian Agricultural Research and Development (CARDI)

ព័ត៌មានបន្ថែមសូមទាក់ទង ការិយាល័យក្សេត្រវិទ្យា និងប្រព័ន្ធកសិកម្ម មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិ.ផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា តាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ ទូរសារលេខ: (៨៥៥-២៣) ២១៩ ៨០០ គេហទំព័រ: www.cardi.org.kh
ទូរអក្សរ: cphaloeun@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh

Cambodian Agricultural Research and Development Institute
(CARDI)





ផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

National Road N$^{o}$ 3, Prateah Lang Commune, Dangkor District,

Phnom Penh, Kingdom of Cambodia.

ទូរស័ព្ទលេខ: +៨៥៥ ២៣ ៦៣១៩ ៦៩៣-៤ ទូរសារលេខ: + ៨៥៥ ២៣ ២១៩ ៨០០

Tel: +855-23 6319 693-4, Fax: +855-23 219 800

ប្រអប់សំបុត្រ ០១ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

P.O. Box 01, Phnom Penh, Kingdom of Cambodia,

E-mail: cardi@cardi.org.kh, Website: www.cardi.org.kh